# គោលការណ៍ណែនាំ

## ចំពោះការរក្សាការពារពីសំណុំរឿងរំលោភបំពាន និងការរុកគួន

*បោះពុម្ពផ្សាយដោយ*

ការិយាល័យរដ្ឋបាលនៃផ្នែកតុលាការរដ្ឋមេន

**ខែមិថុនា ឆ្នាំ 2019**

KHMER/
CAMBODIAN

## ទម្រង់បែបបទតុលាការ

សំណៅអេឡិចត្រូនិកនៃទម្រង់ខាងក្រោម មាននៅលើវិបសៃត៍របស់ផ្នែកតុលាការ តាមអាសយដ្ឋានwww.courts.maine.gov/fees_forms ។ ចំពោះសំណៅបោះពុម្ពលើក្រដាស លោកអ្នកអាចស្នើសុំបានដោយឥតគិតថ្លៃពីការិយាល័យក្រឡាបញ្ជីនៃ តុលាការមណ្ឌល ។

**ដើម្បីចាប់ផ្តើមការការពារពីករណីរំលោភបំពាន ឬការរុកគួន សូមបំពេញទម្រង់ណាមួយខាងក្រោម ៖**

☐ *PA-001 បណ្តឹងស្នើសុំការរក្សាការពារពីការរំលោភបំពាន*( អ្នកដើមចោទ ) *ឬ*

☐ *PA-006 បណ្តឹងស្នើសុំការរក្សាការពារពីការរុកគួន*( អ្នកដើមចោទ ) ។

**ទម្រង់ដែលប្រើទាំងសំណុំរឿង*ការ*ការពារពីការរំលោភបំពាន និងការរុកគួន ៖**

☐ *PA-017 ការជូនដំណឹងសំខាន់ដល់អ្នកដើមចោទ*( អ្នកដើមចោទ ) ( ជាបទល្មើសឧក្រិដ្ឋកម្ម ចំពោះការថ្លែងកុហកតុលាការ ) ( ភាពតម្រូវ ) ។

☐ *PA-005 ព័ត៌មានការផ្តល់សេវាកម្មចំពោះដីការក្សាការពារ* ( អ្នកដើមចោទ ) ( ជួយអ្នកអនុវត្តច្បាប់ តាមរកអ្នកចុងចោទ ដើម្បីផ្តល់ដំណឹងអំពីសំណុំរឿង )( ភាពតម្រូវ ) ។

☐ *PA-015 លិខិតថ្លែងសច្ចារសម្រាប់អាសយដ្ឋាន/លេខទូរស័ព្ទដែលជាការសម្ងាត់*( អ្នកដើមចោទ ) ( រក្សាព័ត៌មានទំនាក់ទំនងជាលក្ខណៈឯកជន ដើម្បីសុវត្ថិភាព )( ជម្រើស ) ។

### ទម្រង់បន្ថែម

☐ *FM-050 លិខិតថ្លែងសច្ចារការផ្តល់ប្រាក់ឧបត្ថម្ភកូន*( នៅក្នុងសំណុំបែបបទសំណុំរឿងការពារពីការរំលោភបំពានបើគូភាគីទាំងពីរមានកូនជាមួយគ្នាជាអនីតិជន ហើយតុលាការនៅមិនទាន់បានចេញដីកាបង្គាប់ឲ្យបង់ប្រាក់ឧបត្ថម្ភកូននៅឡើយ ) ។

☐ *PA-012 ញត្តិមុនការកាត់ក្តីរបស់អ្នកដើមចោទ ដើម្បីបដិសេធបណ្តឹង* ( អ្នកដើមចោទ ) ។

☐ *PA-013 ញត្តិដើម្បីស្នើសុំការពន្យារប្រសិទ្ធភាពនៃដីការក្សាការពារ* ( អ្នកដើមចោទ ) ។

☐ *PA-022 ញត្តិរបស់អ្នកដើមចោទក្រោយការកាត់ក្តីដើម្បីកែប្រែ/ញត្តិដើម្បីបញ្ចប់ប្រសិទ្ធភាពដីការក្សាការពារ*( អ្នកដើមចោទ ) ។

☐ *PA-010 ញត្តិរបស់អ្នកចុងចោទដើម្បីស្នើសុំរំលាយដីកាបណ្តោះអាសន្នសម្រាប់ការរក្សាការពារ ឬ ដើម្បីកែប្រែ/កែសម្រួល ( ដោយមានរួមបញ្ចូលលិខិតថ្លែងសច្ចារ )* ( អ្នកចុងចោទ )

☐ *CR-CV-199 ការជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន* ( អ្នកដើមចោទ និង/ឬអ្នកចុងចោទ តាមភាពចាំបាច់ ) ។

## សំណួរអំពីសំណុំរឿងការពារ ៖ សូមអានខ្លឹមសារនៃគោលការណ៍ណែនាំទាំងស្រុង

### តើខ្ញុំត្រូវដាក់ពាក្យ ចំពោះសំណុំរឿងបែបណា?

បើបច្ចុប្បន្ន អ្នក និងអ្នកចុងចោទ បាន ឬកំពុងតែមានទំនាក់ទំនងស្នេហា ឬមានទំនាក់ទំនងស្និទ្ធស្នាលជាមួយគ្នា ក្នុងចំណោមទំនាក់ទំនងទាំងឡាយ គឺអ្នកអាចដាក់ពាក្យស្នើសុំការរក្សាការពារពីតុលាការ ចំពោះសំណុំរឿងរំលោភបំពាន ។

ដើម្បីដាក់ពាក្យសុំការរក្សាការពារពីតុលាការ ពីករណីរុកគួន គឺមិនចាំបាច់មានទំនាក់ទំនងអ្វីនឹងគ្នាពីមុនឡើយ ។

### តើត្រូវបង់ថ្លៃ ឬចំណាយអ្វីទេ ក្នុងការដាក់ពាក្យសុំការរក្សាការពារពីសំណុំរឿងបែបនេះ?

ការដាក់ពាក្យសុំការរក្សាការពារពីការរំលោភបំពាន គឺមិនមានការចំណាយអ្វីឡើយ

ចំពោះការដាក់ពាក្យសុំការរក្សាការពារពីការរុកគួន គឺអាចមាន ឬមិនមានការចំណាយ ។ សូមអានខ្លឹមសារត្រង់ផ្នែកទី B.6 ដើម្បីបានដឹងព័ត៌មានបន្ថែម ។ ការិយាល័យក្រឡាបញ្ជី នឹងប្រាប់អ្នកពីតម្លៃក្នុងការដាក់ពាក្យ ។ អ្នកអាចស្នើសុំតុលាការមិនឲ្យយកប្រាក់ពីអ្នក ចំពោះការដាក់ពាក្យស្នើសុំការរក្សាការពារនេះ បើអ្នកមិនមានលទ្ធភាពបង់ ។

### តើខ្ញុំត្រូវប្រើទម្រង់មួយណា ឬត្រូវបំពេញព័ត៌មានអ្វីខ្លះ ចំពោះពាក្យស្នើសុំបែបនេះ?

សូមមើលបញ្ជីអំពីទម្រង់ដែលត្រូវបំពេញ និងទម្រង់ជាជម្រើស នៅផ្នែកខាងក្នុងនៃទំព័រមុខរបស់ឯកសារគោលការណ៍ណែនាំនេះ ។

### តើខ្ញុំអាចទទួលបានដីការក្សាការពារបានភ្លាមៗ ពីតុលាការ (ដោយមិនបាច់ប្រាប់ឲ្យអ្នកចុងចោទដឹងជាមុន) ដែរឬទេ?

អាចដែរ បើចៅក្រមមានពេលពិនិត្យមើល*បណ្ដឹង*របស់អ្នកហើយប្រសិនបើចៅក្រមសម្រេចថា ភស្តុតាងដែលអ្នកដាក់ជូន អាចប្រើបានដើម្បីគាំទ្រការចេញដីការក្សាការពារបណ្ដោះអាសន្នបាន ។ ក្រឡាបញ្ជី នឹងប្រាប់អ្នកឲ្យដឹងថាតើពេលណាចៅក្រមមានពេលពិនិត្យមើលពាក្យស្នើសុំដីការក្សាការពារបណ្ដោះអាសន្នរបស់អ្នក ។

បើចៅក្រមសម្រេចថា មិនចាំបាច់ចេញដីការក្សាការពារបណ្ដោះអាសន្នទេនោះ អ្នកអាចសម្រេចបន្តដំណើរទៅមុខ ជាមួយនឹងសវនាការ ឬក៏ដកបណ្ដឹងរបស់អ្នកទៅវិញ (ជាមួយនឹងជម្រើសការដាក់ពាក្យប្ដឹងសារឡើងវិញនាពេលក្រោយ) ។ ការិយាល័យក្រឡាបញ្ជី នឹងជូនដំណឹងដល់អ្នក និងអ្នកចុងចោទ ពីកាលបរិច្ឆេទសវនាការ ។

## តើពេលណាទើបខ្ញុំ និងអ្នកចុងចោទ ត្រូវត្រឡប់មកកាន់តុលាការម្តងទៀត សម្រាប់សវនាការសម្រេច?

ការរក្សាការពារពីការរំលោភបំពាន ៖ សវនាការ ត្រូវបានគ្រោងពេលធ្វើឡើងក្នុងរវាង 21 ថ្ងៃ ។

ការរក្សាការពារពីការរុកគួន ៖ សវនាការ ត្រូវបានគ្រោងពេលធ្វើឡើងជាប្រញាប់ តាមលទ្ធភាពដែលអាចធ្វើបាន តែអាចមិនត្រូវបានគ្រោងពេលធ្វើឡើងក្នុងរវាង 21 ថ្ងៃ ។

សម្រាប់តែព័ត៌មានប៉ុណ្ណោះ

# មាតិកា


សេចក្តីផ្តើម ........ 6

ផ្នែក ក— ការរក្សាការពារពីការរំលោភបំពាន ........ 9

1. តើការរំលោភបំពានគឺជាអ្វី ? ........ 9
2. តើនរណាអាចស្នើសុំដីការក្សាការពារពីការរំលោភបំពាន (អ្នកដើមចោទ)? ........ 10
3. តើនរណាជាអ្នកចុងចោទ ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន? ........ 10
4. តើការរក្សាការពារពីសំណុំរឿងការរំលោភបំពាន ត្រូវចាប់ផ្តើមយ៉ាងដូចម្តេច? ........ 11
5. តើតុលាការមណ្ឌលណាមួយដែលអ្នកដើមចោទគប្បីប្តឹង? ........ 11
6. ប្រាក់កម្រៃ ........ 12
7. ជំនួយស្មារតីសម្រាប់ការបំពេញពាក្យបណ្តឹង ........ 12
8. ដំណើរការសម្រាប់ទទួលបាន ដីការក្សាការពារបណ្តោះអាសន្នពីតុលាការ ........ 13
9. ការរឹតបន្តឹងសិទ្ធិរបស់អ្នកចុងចោទ មិនឲ្យមានជាកម្មសិទ្ធិ មិនឲ្យទទួល ឬមិនឲ្យមានកាំភ្លើង អាវុធគ្រោះថ្នាក់ផ្សេងទៀត ឬគ្រាប់រំសេវ ក្នុងដៃ 13
10. ការផ្តល់សេវាកម្មដល់អ្នកចុងចោទ ........ 15
11. តើសវនាការសម្រេច នឹងត្រូវធ្វើឡើងនៅពេលណា ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន? ........ 16
12. សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកចុងចោទ ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន ។ សិទ្ធិរបស់អ្នក ក្នុងនាមជាអ្នកចុងចោទ ........ 16
13. ប្រសិនបើដីការក្សាការពារបណ្តោះអាសន្នហាមឃាត់អ្នកចុងចោទមិនឲ្យមានអាវុធគ្រោះថ្នាក់ ក្នុងដៃ ........ 18
14. ចំណុចដែលអ្នកត្រូវចងចាំ មុនការបើកសវនាការសម្រេច ........ 19
15. ដីកាដោយមានការយល់ព្រម (ដោយមិនមានសវនាការ) ........ 19
16. តើនឹងមានអ្វីកើតឡើងក្នុងសវនាការសម្រេច? ........ 20
17. តើដំណោះស្រាយអ្វីខ្លះដែលអាចមានរួមក្នុងដីការក្សាការពារពីការរំលោភបំពាន? ........ 21
18. តើដីការក្សាការពារសម្រេចពីការរំលោភបំពានមានប្រសិទ្ធភាពយូរប៉ុណ្ណា? ........ 23
19. តើត្រូវធ្វើដូចម្តេច បើអ្នកចុងចោទប្រព្រឹត្តបំពានដីកាតុលាការ? ........ 23
20. ការប្តូរ ឬការបញ្ចប់ដីការក្សាការពារសម្រេច ........ 23
21. តើត្រូវធ្វើដូចម្តេច បើអ្នកដើមចោទចង់ ពន្យាសុពលភាពនៃដីការក្សាការពារ ........ 24
22. ដីការក្សាការពារពីការរំលោភបំពាន ដែលចេញដោយតុលាការនៅរដ្ឋផ្សេង ........ 25

ផ្នែក ខ— ការរក្សាការពារពីការរុកគួន ....................................................26
1. តើការរុកគួនគឺជាអ្វី? ....................................................26
2. នរណាអាចស្នើសុំការរក្សាការពារពីតុលាការ លើសំណុំរឿងការរុកគួន? ....................................................26
3. តើនរណាជាអ្នកចុងចោទក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន? ........26
4. តើសំណុំរឿងការរក្សាការពារពីការរុកគួនត្រូវចាប់ផ្តើមយ៉ាងដូចម្តេច? ទទួលបានការជូនដំណឹងអំពីការ "បញ្ឈប់ការរុកគួន" ពីមន្ត្រីអនុវត្តច្បាប់ ....................................................26
5. តើតុលាការមណ្ឌលណាមួយដែលអ្នកដើមចោទគប្បីប្តឹង? ..............27
6. ប្រាក់កម្រៃ ....................................................27
7. ជំនួយស្មារតីសម្រាប់ការបំពេញពាក្យបណ្តឹង អំពីការរុកគួន ............27
8. តើអ្នកដើមចោទអាចទទួលបានដីការក្សាការពារបណ្តោះអាសន្នពីការរុកគួន បានដែរឬទេ? ....................................................28
9. តើសវនាការសម្រេចចំពោះសំណុំរឿងការរក្សាការពារពីការរុកគួនត្រូវធ្វើឡើងនៅពេលណា? ....................................................28
10. សេវាកម្មចំពោះអ្នកចុងចោទ ....................................................28
11. សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកចុងចោទក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន ....................................................29
12. ការគ្រោងពេលធ្វើសវនាការសម្រេចក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន ....................................................29
13. ដីកាដោយមានការយល់ព្រម (ដោយគ្មានសវនាការ) ......................30
14. តើនឹងមានអ្វីកើតឡើងនៅក្នុងសវនាការសម្រេច? ..........................30
15. តើដំណោះស្រាយអ្វីខ្លះ អាចត្រូវបានដាក់បញ្ចូលក្នុងដីការក្សាការពារសម្រេចពីការរុកគួន? ....................................................30
16. តើដីការក្សាការពារសម្រេចពីការរំលោភបំពានមានប្រសិទ្ធិភាពយូរប៉ុណ្ណា? ....................................................31
17. តើត្រូវធ្វើដូចម្តេច បើអ្នកចុងចោទប្រព្រឹត្តបំពានដីការក្សាការពាររបស់តុលាការ ពីការរុកគួន? ....................................................31
18. ការកែសម្រួលនិងការពន្យារសុពលភាពនៃដីការក្សាការពារពីការរុកគួន.......31
19. ដីការក្សាការពារពីការរុកគួនដែលបានចេញដោយរដ្ឋផ្សេងទៀត......32
និយមន័យនៃពាក្យគន្លឹះ ....................................................33
ឧបសម្ព័ន្ធ ក— តុលាការមណ្ឌល ....................................................39
ឧបសម្ព័ន្ធ ខ— ការិយាល័យនគរបាលតំបន់....................................................42
ឧបសម្ព័ន្ធ គ— ព័ត៌មានទូទៅ ....................................................43

**ការបដិសេធមិនទទួលខុសត្រូវសំខាន់ៗ**

កិច្ចតម្រូវជាក់លាក់ អំពីសំណុំរឿងរបស់អ្នក មានសរសេរនៅក្នុងច្បាប់ បញ្ញត្តិ និងបទបញ្ជារដ្ឋបាល ។ នេះគឺគ្រាន់តែជាគោលការណ៍ណែនាំតែប៉ុណ្ណោះ ។

សម្រាប់តែព័ត៌មានប៉ុណ្ណោះ

## សេចក្តីផ្តើម

គោលការណ៍ណែនាំនេះ ពន្យល់អំពីរបៀប**ដាក់ពាក្យ**ស្នើសុំដីកា**រក្សាការពារ**បណ្តោះអាសន្ន ឬសម្រេចពីការរំលោភបំពានឬការរក្សាការពារពី**ការរុកគួន** ។ ច្បាប់រដ្ឋមេនអនុញ្ញាតឲ្យជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ឬជនរងគ្រោះពីទំនាក់ទំនងស្នេហា**ជនរងគ្រោះពីការរំលោភបំពានផ្លូវភេទ**ជនរងគ្រោះ**ពីការឈ្លបមើល**ឬជនរងគ្រោះពីការរុកគួន (**ដើមចោទ**) ដើម្បីទទួលបានការរក្សាការពារទាំងរយៈពេលខ្លី និងរយៈពេលវែង ។

ការរំលោភបំពាន អាចរួមបញ្ចូលនូវការធ្វើចេញ**រូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែង**ដោយមានគោលបំណងបង្កការរុកគួន ធ្វើទុក្ខបុកម្នេញ គម្រាម ឬពាក់ព័ន្ធនឹង**ការជួញដូរផ្លូវភេទ**ក៏ដូចជាការរំលោភបំពានតាមរូបភាពផ្សេងៗទៀតផងដែរ ។ សូមមើលផ្នែក ក.1 ។

**ជនជាប់ចោទពីបទ**រំលោភបំពាន រំលោភផ្លូវភេទ ការឈ្លបមើល ឬការរុកគួន (**ចុងចោទ**) អាចតតាំងចំពោះបណ្តឹង ។
លការណ៍ណែនាំនេះក៏មានព័ត៌មានសម្រាប់ទាំងអ្នកដើមចោទ និងអ្នកចុងចោទ (**គូភាគី**) ផងដែរ ។

## តើច្បាប់មានភាពខុសគ្នាដូចម្តេចខ្លះ?

ច្បាប់ការពារពីការរំលោភបំពាន និងការពារពីការរុកគួន មានភាពខុសគ្នាតាមចំណុចមួយចំនួន ។ បើទោះបីជាច្បាប់ទាំងពីរនេះ ជាច្បាប់រដ្ឋប្បវេណី ហើយមានដំណើរការតុលាការ ដូចគ្នាក៏ដោយ ក៏ច្បាប់នីមួយៗ មានភាពតម្រូវរៀងៗខ្លួន ។ ផ្នែក ក នៃគោលការណ៍ណែនាំនេះ ពន្យល់អំពីការរក្សាការពារពីការរំលោភបំពាន រីឯផ្នែក ខ និយាយពីការរក្សាការពារពីការរុកគួន ។ ពេលខ្លះ គេហៅច្បាប់ទាំងពីរនេះរួមគ្នាថាជា "ច្បាប់រក្សាការពារ - protection laws" ។

ច្បាប់រក្សាការពារនេះ មាននៅក្នុងច្បាប់កែសម្រួលឡើងវិញ របស់រដ្ឋមេនដូចខាងក្រោម ៖

> ចំណងជើង 19-A វគ្គទី 4001-4014
> (ការរក្សាការពារពីការរំលោភបំពាន)
>
> ចំណងជើងទី 5 វគ្គទី 4651-4661 (ការរក្សាការពារពីការរុកគួន) និង
>
> ចំណងជើង 17 និង 17-A (វគ្គក្រមព្រហ្មទណ្ឌរដ្ឋមេន ការយោងទៅក្នុង ចំណងជើង 19-A និង ចំណងជើង 5) ។

ច្បាប់កែសម្រួលឡើងវិញ របស់រដ្ឋមេន អាចបើកមើលអនឡាញ បាននៅឯ ៖>។ ច្បាប់នេះ មានរួមទៅដោយភាសាផ្លូវច្បាប់ និងគិច្ចតម្រូវយ៉ាងជាក់ច្បាស់ថាចៅក្រមយកវាមកប្រើនៅពេលសម្រេចសេចក្តីសំណុំរឿងនៅក្រោមច្បាប់រក្សាការពារ ។

## ការប្រើទម្រង់តុលាការ

តុលាការមណ្ឌលរដ្ឋមេន មានទម្រង់សម្រាប់ឲ្យអ្នកប្រើ ក្នុងសំណុំរឿងការរក្សាការពារ ។ ក្រឡាបញ្ជីតុលាការមណ្ឌលអាចផ្តល់សំណៅនៃទម្រង់នានា

ដែលត្រូវបំពេញ ហើយអាច ឆ្លើយនឹងសំណួរទូទៅ ។ ក្រឡាបញ្ជី មិនអាចជួយអ្នកក្នុងការសម្រេចថា តើត្រូវប្រើទម្រង់ណាមួយ ឬក៏ប្រាប់អ្នកថាត្រូវបំពេញព័ត៌មានអ្វីចូលក្នុងទម្រង់នោះឡើយ ។ ក្រឡាបញ្ជី និងបុគ្គលិកតុលាការ មិនមានសិទ្ធិផ្តល់ដំបូន្មានផ្លូវច្បាប់បានឡើយ ។

ទម្រង់ជាច្រើនអាចបំពេញអនឡាញ គឺគ្រាន់តែប្រើកុំព្យូទ័រ រួចបោះពុម្ព ។ អ្នកក៏អាចបំពេញព័ត៌មានក្នុងទម្រង់ដោយដៃបានដែរ ។

ប្រសិនបើអ្នកមិនមានកុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព សម្រាប់ប្រើ អ្នកអាចទៅបណ្ណាល័យដែលមានកុំព្យូទ័រសាធារណៈ ហើយសុំបណ្ណារក្សឲ្យជួយអ្នករកទម្រង់ ឬអ្នកអាចប្រើកុំព្យូទ័រ និងម៉ាស៊ីនបោះពុម្ព នៅកន្លែងផ្សេងទៀត ។ បញ្ជីនៃបណ្ណាល័យសាធារណៈ មាននៅឯ ៖
www.maine.gov/msl/libs/directories/public.

ទម្រង់សម្រាប់ទាំងដើមចោទ និងអ្នកចុងចោទ គឺមាននៅឯ
www.courts.maine.gov/fees_forms/forms/index.shtml#pa ។

បញ្ជីឈ្មោះទម្រង់ សម្រាប់សំណុំរឿងការរក្សាការពារពីការរំលោភបំពាន និងការរុកគួន សម្រាប់ទាំងអ្នកដើមចោទ និងអ្នកចុងចោទ ក៏មានផ្តល់ជូនផងដែរ នៅត្រង់ក្របមុខផ្នែកខាងក្នុងនិងទំព័របន្ទាប់នៃសៀវភៅគោលការណ៍ណែនាំនេះ ។

## សៀវភៅគោលការណ៍ណែនាំ នេះគឺប្រើសម្រាប់តែផ្តល់ជូនជាព័ត៌មានតែប៉ុណ្ណោះ

ការទៅកាន់តុលាការ ជាពិសេសបើអ្នកមិនមានមេធាវី គឺអាចធ្វើឲ្យអ្នករងសម្ពាធ និងមានភាពប្រឈម ។ សៀវភៅគោលការណ៍ណែនាំនេះ ត្រូវបានសរសេរឡើងសម្រាប់ជួយអ្នកដែលត្រូវទៅកាន់តុលាការដោយមិនមានអ្នកតំណាង ដែលពាក់ព័ន្ធនឹងសំណុំរឿងការរក្សាការពារ ។ ដើម្បីធ្វើឲ្យសៀវភៅនេះ ងាយអាន វគ្គឃ្លាមួយចំនួននៃច្បាប់ បទបញ្ញត្តិ ឬបទបញ្ជារដ្ឋបាល ដែលពាក់ព័ន្ធ ត្រូវបានសរសេរឲ្យខ្លី ឬសង្ខេបសេចក្តីឲ្យងាយយល់ ។

នៅពេលដែលគោលការណ៍ណែនាំ និយាយសំដៅលើអ្វីដែលអ្នកដើមចោទ ឬអ្នកចុងចោទត្រូវ ឬគួរធ្វើ គឺយើងប្រើសព្វនាម “អ្នក” ។ “អ្នក” អាចសំដៅលើភាគីណាមួយក្នុងសំណុំរឿង គឺអាស្រ័យលើភាពជាក់លាក់នៃវគ្គណាមួយនៃគោលការណ៍ណែនាំនេះ ។

ក្នុងពេលដែលយើងខ្ញុំបានព្យាយាមធានាឲ្យបានថា ព័ត៌មាននៅក្នុងសៀវភៅនេះ មានភាពត្រឹមត្រូវ និងច្បាស់លាស់ សូមកុំភ្លេចថា ភាសាដែលគេប្រើក្នុងច្បាប់ និងប្រភពច្បាប់ផ្សេងៗទៀត គឺជាអ្វីដែលគេយកជាគោល ។ ប្រសិនបើមានខ្លឹមសារណាមួយក្នុងសៀវភៅនេះ មានភាពផ្ទុយពីខ្លឹមសារច្បាប់ គឺខ្លឹមសារច្បាប់ ជាប្រភពដែលមានទម្ងន់ ។

លើសពីនេះសៀវភៅគោលការណ៍ណែនាំនេះ *ពណ៌នាអំពីនីតិវិធីទូទៅ និងកិច្ចតម្រូវ*នៃច្បាប់ដែលពាក់ព័ន្ធទាំងអស់ ។ ការសម្រេចរបស់តុលាការចំពោះ

សំណុំរឿងរបស់បុគ្គលម្នាក់ៗ គឺអាស្រ័យលើការពិតជាក់លាក់ និងកាលៈទេសៈទាំងអស់ ចំពោះសំណុំរឿងនីមួយ ៗ ។

យើងបានដាក់បញ្ចូលវាក្យស័ព្ទងាយៗ អំពីពាក្យគន្លឹះរបស់ច្បាប់ នៅផ្នែកខាងចុងនៃ សៀវភៅនេះ ។ ពាក្យដែលបោះពុម្ព**ដិត**គឺជាពាក្យដែលមានបញ្ជាក់និយមន័យនៅក្នុងវគ្គនេះ ។

សម្រាប់តែអ្នកព័ត៌មានប៉ុណ្ណោះ

## ការបញ្ជាក់សម្រេច អំពីការដាក់ពាក្យប្ដឹង ក្នុងសំណុំរឿងតុលាការណាមួយ

សំណុំរឿងការរក្សាការពារពីការរំលោភបំពាន ឬការរុកគួន ដូចគ្នានឹងសំណុំរឿងផ្សេងទៀតដែរ គឺត្រូវចាប់ផ្ដើមតែនៅពេលដែលចាំបាច់ឲ្យតុលាការពាក់ព័ន្ធ ដើម្បីជួយការពារមនុស្ស ឬទ្រព្យសម្បត្តិពីគ្រោះថ្នាក់ ។ នៅពេលអ្នកចុះហត្ថលេខាលើទម្រង់របស់តុលាការ ឬលើ**លិខិតថ្លែងសច្ចារ**គឺមានន័យថា អ្នកកំពុងតែនិយាយថា ព័ត៌មានទាំងអស់នៅក្នុងឯកសារនោះ គឺសុទ្ធតែជាការពិត តាមអ្វីដែលអ្នកដឹង តាមព័ត៌មានដែលអ្នកមាន និងតាមជំនឿរបស់អ្នក ។ ច្បាប់តុលាការចែងថា បុគ្គលណាដែលដឹងថាខ្លួនកំពុងតែថ្លែងកុហក នៅក្នុងឯកសារ ឬទម្រង់តុលាការ ឬនៅឯសវនាការតុលាការ គឺត្រូវទទួលខុសត្រូវចំពោះការចំណាយ របស់តុលាការ ឬក្រួមទាំងថ្លៃមេធាវី ដែលគូភាគីម្ខាងទៀតត្រូវបង់ ។

ហើយវាក៏ជាឧក្រិដ្ឋកម្មផងដែរ ក្នុងការធ្វើសេចក្ដីថ្លែងការក្លែងក្លាយនៅក្រោមសម្បថនៅក្នុងឯកសារ ឬសវនាការតុលាការ ។ លើសពីនេះ ការប្រើប្រាស់ដោយឥតប្រយោជន៍របស់ឪពុកម្ដាយចំពោះដំណើរការនៃការប្រឹងប្រែងកើនបាននូវសារប្រយោជន៍ក្នុងការលះលែង ឬ **ចំនួនភាគរយ** ដែលសំណុំរឿងត្រូវបានចាត់ទុកដោយតុលាការក្នុងសំណុំរឿងការលះលែង និង ចំនួនភាគរួយ នៅពេលសម្រេចអំពីឯកសិទ្ធិនឹងការទទួលខុសត្រូវរបស់ឪពុក ឬ ម្ដាយ ។

## ផ្នែក"គ៉ "ការរក្សាការពារពីការរំលោភបំពាន

### 1.តើការរំលោភបំពានគឺជាអ្វី ?

- គឺការប៉ុនប៉ងធ្វើឲ្យមាន ឬការធ្វើឲ្យមានរបួសស្នាមលើរាងកាយ ឬប៉ះពាល់បែបវាយដំរាងកាយជនរងគ្រោះ ឬក្រួមទាំងការរំលោភបំពានខាងផ្លូវភេទផងដែរ
- ការប៉ុនប៉ងធ្វើឲ្យ ឬការធ្វើឲ្យភាគីម្ខាងទៀតស្ថិតក្នុងភាពភ័យខ្លាចចំពោះរបួសលើរាងកាយ តាមរយៈការគម្រាមកំហែង ការរុកគួន ឬការបង្ហាញអាកប្បកិរិយាចង់ធ្វើទារុណកម្មភាគីម្ខាងទៀត ។
- ការបង្ខំជនម្នាក់ដោយកម្លាំង គម្រាមប្រើកម្លាំង ឬការបំភ័យឲ្យធ្វើ ឬមិនឲ្យធ្វើអ្វីមួយដែលភាគីម្ខាងទៀតមានឯកសិទ្ធិចង់ធ្វើ ឬមិនចង់ធ្វើក៏បាន
- ការដាក់កម្រិតធ្ងន់ធ្ងរដោយចេតនា ចំពោះសកម្មភាពនៃជនម្នាក់ទៀតដោយគ្មានការយល់ព្រមរបស់ជននោះ
- ការទាក់ទងជនម្នាក់ដោយការគម្រាមកំហែងថានឹងប្រព្រឹត្តិ ឬគម្រាមថានឹងបង្កឲ្យមានការ ប្រព្រឹត្តិ បទឧក្រិដ្ឋនៃអំពើហិង្សា ដែលមានគ្រោះថ្នាក់ ចំពោះជីវិតមនុស្ស

សម្រាប់ព័ត៌មានប៉ុណ្ណោះ។

- ការដើរតាម ឬការមានវត្តមាននៅឯ ឬឬមានវត្តមាននៅក្នុងទីកន្លែងនៃផ្ទះសំបែង សាលា កន្លែងប្រកបមុខរបរ ឬ កន្លែងធ្វើការរបស់អ្នកដើមចោទម្តងហើយម្តងទៀត ដោយមិនមានមូលហេតុសមរម្យ
- ដោយខ្លួនបានដឹង ហើយមានការប៉ុនប៉ងបង្កការរុកគួន ធ្វើទុក្ខទោស ឬគម្រាមកំហែង ការចែកចាយរូបភាពឯកជន**រូបភាពអាសអាភាសជាក់ស្តែង**របស់អ្នកដើមចោទ ឬរូបរបស់នរណាម្នាក់ដោយគ្មានការយល់ព្រមពីសមីខ្លួន
- ការជាប់ពាក់ព័ន្ធនឹងការ**ជួញដូរផ្លូវភេទ**ឬ**ការធ្វើឲ្យកាន់តែធ្ងន់ធ្ងរខ្លាំងចំពោះការជួញដូរផ្លូវភេទ**ឬ
- **ការកេងប្រវ័ញ្ចហិរញ្ញវត្ថុ**ឬកេងប្រវ័ញ្ចហិរញ្ញវត្ថុដោយចេតនាដោយដឹងខ្លួន ឬការព្រងើយកន្តើយ(?) ចំពោះការធ្វើឲ្យខូចខាតលើអ្វីដែលជាតម្រូវការចាំបាច់ បើការរំលោភបំពាននេះ មានពាក់ព័ន្ធនឹងនីតិជនអសមត្ថភាព នីតិជនរស់ក្រោមបន្ទុកអ្នកដទៃ ឬនីតិជនដែលមានអាយុចាប់ពី 60 ឆ្នាំ ឡើងទៅ ។

ប្រសិនបើសកម្មភាពនោះ មិនបង្កឲ្យមានការរំលោភបំពាន តាមអ្វីដែលបានកំណត់យ៉ាងជាក់ច្បាស់នៅក្នុងច្បាប់ការវាយរំលោភបំពាន អ្នកដើមចោទ ត្រូវស្វែងរកភាពមានសិទ្ធិទទួលបាន ដីការក្សាការពារពីតុលការ ។ សូមមើល ផ្នែក ខ នៃសៀវភៅគោលការណ៍ណែនាំនេះ ។

## 2.តើនរណាអាចស្នើសុំដីការក្សាការពារពីការរំលោភបំពាន (អ្នកដើមចោទ)?

- **នីតិជន**ដែលជាជនរងគ្រោះ ឬជាគោលដៅនៃការរំលោភបំពាន
- នីតិជនធ្វើជាតំណាង **កុមារអនីតិជន** ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន
- អនី **តិជនមិនស្ថិតក្រោមអាណាព្យាបាលអ្នកដទៃ**ឬ
- នីតិជន**អសមត្ថភាព**ឬ**នីតិជនរស់ក្រោមបន្ទុកអ្នកដទៃ**ដែលតំណាងដោយ**អាណាព្យាបាល**។

## 3.តើនរណាជាអ្នកចុងចោទ ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន?

- ប្តី ឬ ប្រពន្ធ ឬ អតីតប្តីឬប្រពន្ធ
- ដៃគូរួមផ្ទះ ឬ អតីតដៃគូរួមផ្ទះ
- ដៃគូដើរលេងជាមួយគ្នាបច្ចុប្បន្ន ឬ អតីតដៃគូដើរលេងជាមួយគ្នា ឬ គូស្រករស្និទ្ធស្នាល
- សមាជិកបច្ចុប្បន្ន ឬ អតីតសមាជិកនៃ **គ្រួសារ ឬ សមាជិកនៃក្រុមគ្រួសារ**

- អ្នក **ផ្តល់ការថែទាំ ឬ សមាជិកគ្រួសារជាសាច់ឆ្ងាយជាអ្នកថែទាំដែលមិនទទួលបានប្រាក់កម្រៃ** ប្រសិនបើអ្នកដើមចោទ មានអាយុ 60 ឆ្នាំ ឡើងលើ ឬ
- នរណាម្នាក់ ដែលបានប្រព្រឹត្តិរំលោភផ្លូវភេទ ពាក់ព័ន្ធនឹងការឈ្លបមើល ការជួញដូរផ្លូវភេទ ការធ្វើឲ្យសកម្មភាពជួញដូរផ្លូវភេទកាន់តែមានសភាពធ្ងន់ធ្ងរ ឬការចែកចាយដោយដឹងខ្លួននូវរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែងរបស់ដើមចោទ ដោយមិនមានការយល់ព្រមពីសមីខ្លួន ។

## 4. តើការរក្សាការពារពីសំណុំរឿងការរំលោភបំពាន ត្រូវចាប់ផ្តើមយ៉ាងដូចម្តេច?

**ដើមចោទ៖**

1. បំពេញព័ត៌មានក្នុង ***ពាក្យបណ្តឹង****ដើម្បីស្នើសុំការរក្សាការពារពីការរំលោភបំពាន (PA-001 ) (បណ្តឹង )* និងទម្រង់ផ្សេងទៀតដែលពាក់ព័ន្ធ (សូមមើលបញ្ជីទម្រង់នៅទំព័រដើមនៃសៀវភៅគោលការណ៍ណែនាំនេះ ) ។

2. ត្រូវចុះហត្ថលេខានៅមុខសារការី មេធាវី ឬក្រឡាបញ្ជីតុលាការ រួចយកទម្រង់នេះ ទៅឲ្យការិយាល័យក្រឡាបញ្ជីតុលាការមណ្ឌល ។

អ្នកអាចទៅកាន់ការិយាល័យក្រឡាបញ្ជីដោយផ្ទាល់ ដើម្បីបំពេញ និងដាក់ស្នើទម្រង់ទាំងអស់នេះ ឬក៏អ្នកអាចបំពេញទម្រង់ទាំងអស់នេះ អនឡាញ រួចបោះពុម្ព រួចយកវាមកដាក់ស្នើនៅតុលាការមណ្ឌល ។ ការិយាល័យក្រឡាបញ្ជី អាចជួយអ្នកចំពោះកំហុសការស្មៀនក្នុងការបំពេញទម្រង់បែបបទ តែគេមិនអាចប្រាប់អ្នកថាត្រូវបំពេញព័ត៌មានអ្វីខ្លះ ឬផ្តល់ដំបូន្មានផ្លូវច្បាប់ដល់អ្នកបានឡើយ ។

ដីការក្សាការពារពីការរំលោភបំពាន មានប្រសិទ្ធភាព នៅពេលដែលបានចុះហត្ថលេខាដោយចៅក្រម ។ ទោះជាយ៉ាងណាក៏ដោយ ដីកានេះត្រូវតែប្រគល់ទៅឲ្យអ្នកចុងចោទ មុនពេលដែលជននោះ អាចរងការចោទប្រកាន់បទឧក្រិដ្ឋ ចំពោះការប្រព្រឹត្តិរំលោភ ដីកាតុលាការនេះ បើអ្នកចុងចោទនៅមិនទាន់បានទទួលដំណឹងជាក់ស្តែងជាមុន អំពីការចេញដីកាតុលាការនេះនោះ ។ សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្ម ចំពោះអ្នកចុងចោទ សូមអានផ្នែក ក.10 ។

## 5. តើតុលាការមណ្ឌលណាមួយដែលអ្នកដើមចោទគប្បីប្តឹង?

ធ្វើដំណើរទៅកាន់ទីតាំងរបស់តុលាការមណ្ឌល នៅកន្លែងដែលអ្នករស់នៅ នៅកន្លែងដែលចុងចោទរស់នៅ ឬកន្លែងដែលអ្នកកំពុងតែនៅបច្ចុប្បន្ន បើអ្នកបានរើចេញពីផ្ទះ ដោយសារមូលហេតុសុវត្ថិភាពផ្ទាល់ខ្លួន ។

បញ្ជីឈ្មោះតុលាការមណ្ឌល មានសរសេរជូននៅខាងចុងនៃសៀវភៅគោលការណ៍ណែនាំនេះ គឺនៅក្នុងឧបសម្ព័ន្ធ ក និងតាមអនឡាញនៅឯ ៖ ។

## 6. ប្រាក់កម្រៃ

ការដាក់ពាក្យប្ដឹងឬការផ្ដល់សេវាកម្ម ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន គឺអ្នកមិនបាច់បង់ថ្លៃអ្វីឡើយ ។

## 7. ជំនួយស្មារតីសម្រាប់ការបំពេញពាក្យបណ្ដឹង

សូមបំពេញព័ត៌មានក្នុងទម្រង់*ពាក្យបណ្ដឹង*ឲ្យបានចប់ចុងចប់ដើម ។

ត្រូវផ្ដល់សេចក្ដីលំអិតឲ្យបាន តាមដែលអាចធ្វើទៅបាន ។ តើ*អ្នកចុងចោទ*បានធ្វើ ឬ និយាយអ្វីជាក់លាក់ តើអ្នក (ឬ ប្រសិនបើអ្នកកំពុងតែដាក់ពាក្យប្ដឹងជំនួសកូនរបស់អ្នកដើមចោទ) រងរបួស ឬរគ្រោះថ្នាក់អ្វីខ្លះ ឬស្ថិតក្នុងការរងទុក្ខពីគ្រោះថ្នាក់អ្វីខ្លះ? សូមកុំគ្រាន់តែថ្លែងថា “អ្នកចុងចោទបានលបដើរតាមខ្ញុំ” ឬ “អ្នកចុងចោទបានគម្រាមបង្កគ្រោះថ្នាក់ដល់កូនខ្ញុំ” ។

ផ្ដល់សេចក្ដីលំអិតចំពោះការវាយរំលោភបំពានធ្ងន់ធ្ងរ និង ថ្មីថ្មោងបំផុតជាមុន សិន ។ ត្រូវប្រាកដថាបានដាក់បញ្ចូលនូវកាលបរិច្ឆេទ និងពេលវេលា ។ ប្រសិនបើអ្នកមិនចង់ឲ្យអ្នកចុងចោទដឹងអំពីទីកន្លែងដែលអ្នកកំពុងស្នាក់នៅដោយសារមូលហេតុសុវត្ថិភាព សូមបំពេញទម្រង់ និងដាក់ស្នើបែបបទ ***លិខិតថ្លែងសច្ចារ*** *សម្រាប់ស្នើសុំលាក់បាំងអាសយដ្ឋាន/លេខទូរស័ព្ទ* (PA-015) ។ អ្នកចុងចោទនឹងមិនអាចមើលឃើញអាសយដ្ឋានបច្ចុប្បន្ន ឬ លេខទូរស័ព្ទបច្ចុប្បន្នរបស់អ្នកឡើយ ។ ទោះជាយ៉ាងណាក៏ដោយ តុលាការត្រូវការព័ត៌មានទំនាក់ទំនងរបស់អ្នក ដើម្បីឲ្យការិយាល័យក្រឡាបញ្ជី អាចទាក់ទងអ្នក អំពីសំណុំរឿងរបស់អ្នក ។

ផ្នែកចុងក្រោយនៃទម្រង់ *បណ្ដឹង* ស្នើសុំឲ្យអ្នកគ្រីសក្នុងប្រអប់សម្រាប់ **ដំណោះស្រាយ** ដែលអ្នកកំពុងតែស្នើសុំ ។ ត្រូវប្រាកដថាបានគូសសញ្ញាជ្រើសរើសក្នុងប្រអប់ណាមួយ ឬប្រអប់ទាំងអស់ដែលអ្នកចង់ឲ្យតុលាការពិចារណា ។

សូមប្រាប់ក្រឡាបញ្ជីឲ្យដឹង អំពីការផ្លាស់ប្ដូរអាសយដ្ឋានរបស់អ្នក ។ ដើម្បីផ្ដល់ព័ត៌មានទំនាក់ទំនងដល់តុលាការ អ្នកអាចប្រើទម្រង់*ការជូនដំណឹងអំពីការប្ដូរអាសយដ្ឋាន (CV/CR-199)* ។

## ស្ថានភាពពិសេស

### រូបភាពអាសអាភាសជាក់ស្ដែង

បើសំណុំរឿងរបស់អ្នក មានការពាក់ព័ន្ធនឹងអ្នកចុងចោទបញ្ចេញរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្ដែងរបស់អ្នក ដោយគ្មានការយល់ព្រមពីអ្នក នៅពេលនោះ រូបភាពណាមួយដែលអ្នកដាក់ភ្ជាប់មកជាមួយនឹង*ពាក្យបណ្ដឹង*នឹងត្រូវស្ថិតក្រោមការប្រថាប់ត្រាដោយស្វ័យប្រវត្តិ ។ នេះមានន័យថា រូបភាពនោះនឹងមិនត្រូវអាចយកមកមើលដោយ ឬ បញ្ចេញទៅឲ្យសាធារណជនបានដឹងឡើយ ។ អ្នកចុងចោទ និងមេធាវីរបស់ភាគីចុងចោទ អាចមើលរូបភាពទាំងនោះបានតែនៅតុលាការ ហើយអាចសុំបើកមើលបានសម្រាប់តែករណីរៀបចំ ដើម្បីឆ្លើយតបចំពោះ*ពាក្យបណ្ដឹងតែប៉ុណ្ណោះ*។

### កាំភ្លើង ឬអាវុធគ្រោះថ្នាក់

តុលាការ អាចហាមឃាត់អ្នកចុងចោទមិនឲ្យកាន់កាប់កាំភ្លើង ឬអាវុធគ្រោះថ្នាក់ដទៃទៀត ក្នុងសំណុំរឿងការរក្សាការពារ ប្រសិនបើស្ថានភាពនោះស្ថិតក្រោមល័ក្ខខ័ណ្ឌជាក់លាក់មួយចំនួន ។ សូមអានខ្លឹមសារត្រង់ផ្នែក ក.9 សម្រាប់ព័ត៌មានលំអិត ។

## 8. ដំណើរការសម្រាប់ទទួលបាន ដីការក្សាការពារបណ្តោះអាសន្ន ពីតុលាការ

ចៅក្រមអាចចេញឲ្យអ្នកនូវ **ដីកាបណ្តោះអាសន្ន** បើចៅក្រម ជឿថា ព័ត៌មានដែលអ្នកផ្តល់ជូន មានទម្ងន់សមនឹងតម្លៃរបស់ ដីកាតុលាការ ។

ក្រឡាបញ្ជីនឹងប្រាប់អ្នកឲ្យបានដឹង ថាតុលាការមានពេលពិនិត្យ *បណ្តឹង* របស់អ្នកដែរឬទេ នៅពេលអ្នកដាក់ពាក្យប្តឹង ហើយក៏ប្រាប់អ្នកផងដែរ ថាជាបន្តមកទៀត ត្រូវមានអ្វីកើតឡើង ។

គេអាចសុំឲ្យអ្នករង់ចាំនៅឯតុលាការ ដើម្បីចាំចៅក្រមពិនិត្យ *បណ្តឹង* របស់អ្នក ។ ត្រូវធ្វើតាមការណែនាំរបស់ក្រឡាបញ្ជី ។

តុលាការអាចសម្ភាសន៍អ្នក ឬ សួរអ្នកនូវសំណួរបន្ថែមអំពីការរំលោភបំពាន ។ បើចៅក្រម ជឿថា ព័ត៌មានដែលអ្នកបានផ្តល់ឲ្យ មានទម្ងន់ដើម្បីរកដំណោះស្រាយបន្ទាន់ ចៅក្រមនឹងចុះហត្ថលេខាលើ ដីកាតុលាការ ។ ការរក្សាការពារបណ្តោះអាសន្នអាចរួមបញ្ចូលនូវ ដំណោះស្រាយខ្លះៗ ឬទាំងអស់ដែលអ្នកបានស្នើសុំនៅក្នុង *បណ្តឹង* ។

ដីការក្សាការពារបណ្តោះអាសន្ន មានប្រសិទ្ធិភាព នៅពេលដែលមានការចុះហត្ថលេខាដោយចៅក្រម ប៉ុន្តែ ដីកានោះត្រូវតែប្រគល់ទៅឲ្យចុងចោទ មុនពេលដែលជននោះ អាចរងការចោទប្រកាន់បទឧក្រិដ្ឋ ចំពោះការប្រព្រឹត្តិរំលោភ ដីកាតុលាការ បើចុងចោទនៅមិនទាន់បានទទួលដំណឹងជាក់ស្តែងជាមុន អំពីការចេញ ដីកាតុលាការ ទេនោះ ។

តុលាការនឹងគ្រោងពេលសវនាការសម្រេចក្នុងរវាង 21 ថ្ងៃក្រោយកាលបរិច្ឆេទដែលអ្នកបានដាក់ពាក្យប្តឹង ។ ដីការក្សាការពារសម្រេចពីការរំលោភបំពាន អាចមានរយៈពេលពីរ (2) ឆ្នាំ ។

ប្រសិនបើអ្នកដកសំណុំរឿងចេញមុនពេលធ្វើសវនាការសម្រេច ដីការក្សាការពារបណ្តោះអាសន្នដែលតុលាការបានផ្តល់ឲ្យអ្នក នឹងលែងមានប្រសិទ្ធភាពទៀតហើយ ។

## 9. ការរឹតបន្តឹងសិទ្ធិរបស់អ្នកចុងចោទ មិនឲ្យមានជាកម្មសិទ្ធិ មិនឲ្យទទួល ឬមិនឲ្យមានកាំភ្លើង អាវុធគ្រោះថ្នាក់ផ្សេងទៀត ឬគ្រាប់រំសេវ ក្នុងដៃ

### ច្បាប់រដ្ឋមេន

ច្បាប់របស់រដ្ឋមេនអនុញ្ញាតឲ្យចៅក្រមអាចហាមឃាត់ (ហាមប្រាម) អ្នកចុងចោទមិនឲ្យមានកាំភ្លើង ឬ អាវុធគ្រោះផ្សេងទៀត ជាកម្មសិទ្ធិ នៅក្នុង

ដីការក្សាការពារបណ្តោះអាសន្ន ដីការក្សាការពារសម្រេច ពីសំណុំរឿងរំលោភបំពាន ។ មុនចៅក្រមអាចចេញដីកា សំណុំរឿងរបស់អ្នកត្រូវស្ថិតក្នុងស្ថានភាពខាងក្រោម ។

ដើម្បីហាមឃាត់មិនឲ្យអ្នកចុងចោទ កាន់កាប់អាវុធគ្រោះថ្នាក់ ចៅក្រមត្រូវរកឃើញថា ៖

- ការរំលោភបំពាន គឺពាក់ព័ន្ធនឹងការប្រើ ឬគម្រាមប្រើកាំភ្លើង ឬអាវុធគ្រោះថ្នាក់ *ឬ*
- ការកើនឡើងនូវហានិភ័យពីការរំលោភបំពានភ្លាមៗដែលកើតឡើងចំពោះអ្នក (អ្នកដើមចោទ) ឬកុមារជាអនីតិជននៅក្នុងផ្ទះ ។

អ្នកត្រូវផ្តល់ព័ត៌មានឲ្យបានជាក់លាក់ និងលំអិតចំពោះការប្រើ ឬការគម្រាមប្រើអាវុធ នៅក្នុង*ពាក្យបណ្តឹង*។

## ច្បាប់សហព័ន្ធ

អាស្រ័យលើភាពពិតជាក់លាក់នៃសំណុំរឿង ច្បាប់សហព័ន្ធក៏អាចប្រើបានចំពោះសិទ្ធិរបស់ចុងចោទ អំពីការកាន់កាប់ ទទួល ឬមានក្នុងដៃ នូវកាំភ្លើង ឬគ្រាប់រំសេវនៅក្នុង **ដីកាសម្រេចផងដែរ** ។

ដើម្បីអាចប្រើការហាមឃាត់របស់សហព័ន្ធ ក្នុងសំណុំរឿងនេះ ចុងចោទត្រូវបានទទួលដំណឹងជាក់ស្តែង និងមានឱកាសចូលរួមសវនាការ ។

នៅក្នុង ដីការក្សាការពារ ចៅក្រមត្រូវរកឃើញការពិត**ជាក់លាក់**ដែលបញ្ជាក់ថា ៖

- អ្នកចុងចោទ បានបង្កការគម្រាមកំហែងដែលគួរឲ្យជឿជាក់ចំពោះសុវត្ថិភាពរាងកាយ របស់អ្នកដើមចោទ ឬចំពោះកុមារអនីតិជននៅក្នុងផ្ទះ *ឬ*
- ដីកា ត្រូវតែហាមឃាត់យ៉ាងច្បាស់លាស់ មិនឲ្យអ្នកចុងចោទប្រើប៉ុនប៉ងប្រើ ឬ គម្រាមប្រើកម្លាំង មកលើអ្នកដើមចោទ ឬកុមារអនីតិជននៅក្នុងគ្រួសារ ដែលអាចមានមូលហេតុសមរម្យថាអាចបង្កឲ្យមានរបួសស្នាមលើរាងកាយ ។ (សូមមើលចំណងជើង 18 នៃក្រមសហរដ្ឋអាមេរិក វគ្គ 922(g)(8))។

ខ្លឹមសារក្នុងវគ្គផ្សេងទៀតនៃច្បាប់សហព័ន្ធ អាចពាក់ព័ន្ធទៅនឹងការហាមឃាត់នេះ ឬក៏ផ្តល់នូវការលើកលែងចំពោះការហាមឃាត់នេះ ។ ត្រូវស្វែងរកជំនួយផ្លូវច្បាប់ បើអ្នកមានសំណួរថាតើការហាមឃាត់របស់សហព័ន្ធមិនឲ្យចុងចោទកាន់កាប់អាវុធ អាចប្រើបាន ឬពិតជាប្រើបានក្នុងសំណុំរឿងរបស់អ្នកដែរឬទេ ។

## ការផ្តល់ព័ត៌មានអំពីអាវុធគ្រោះថ្នាក់

### អ្នកដើមចោទ ៖

ប្រសិនបើអ្នកដឹងថា អ្នកចុងចោទមានអាវុធគ្រោះថ្នាក់ប្រភេទណានៅក្នុងដៃ ត្រូវប្រាកដថាបានរៀបរាប់អំពីអាវុធនោះ ឲ្យបានលំអិត តាមដែលអាចធ្វើទៅបាន ។ រៀបរាប់ពីប្រភេទអាវុធ ចំនួនអាវុធ ភិនភាគអាវុធ និងទីកន្លែងលាក់ទុក ។

## 10.ការផ្តល់សេវាកម្មដល់អ្នកចុងចោទ

បើតុលាការចេញដីការក្សាការពារបណ្តោះអាសន្ន តុលាការជាទូទៅនឹងរៀបចំសេវាកម្មចំពោះចុងចោទ ។ “សេវាកម្ម” ឬ “ការផ្តល់សេវាកម្ម” ដល់នរណាម្នាក់ មានន័យថា ការផ្តល់ដំណឹងអំពីសំណុំរឿង ទៅឲ្យភាគីចុងចោទ បានដឹង ។ មន្ត្រីអនុវត្តច្បាប់ (ជំនួយការនគរបាលតំបន់ ឬមន្ត្រីនគរបាលមូលដ្ឋាន) នឹងផ្តល់សេវាកម្មដល់អ្នកចុងចោទ ដោយផ្ទាល់ (ដែលគេហៅផងដែរថាផ្តល់ដំណឹង “ដោយផ្ទាល់ដៃ”) ។ម្តងម្កាលតុលាការអាចស្នើសុំអ្នកដើមចោទដែលយល់ព្រមធ្វើបែបនោះ ដើម្បីយកសំណៅក្រដាសស្នាមតុលាការ ទៅឲ្យនាយកដ្ឋាននគរបាល ឬ ការិយាល័យនគរបាលតំបន់ ដើម្បីពន្លឿនសេវាកម្មទៅលើអ្នកចុងចោទ ។ គេមិនតម្រូវឲ្យធ្វើកិច្ចការនេះឡើយ ។

បន្ថែមពីលើសំណៅជាក្រដាស សំណៅជាអេឡិចត្រូនិក នៃឯកសារតុលាការ ក៏នឹងត្រូវបញ្ជូនទៅឲ្យមន្ត្រីអនុវត្តច្បាប់ផងដែរ ។ ឧទាហរណ៍ បើជួបអ្នកចុងចោទ នៅតាមភ្លើងស្តុប មន្ត្រីនគរបាលតំបន់ ឬមន្ត្រីនគរបាលមូលដ្ឋាន នឹងប្រគល់ឯកសារតុលាការ ដល់រូបគេ ។

ឯកសារនេះ នឹងនៅតែត្រូវប្រគល់ទៅឲ្យអ្នកចុងចោទ បើទោះបីជាអ្នកដូរចិត្ត ហើយសម្រេចមិនប្រគល់ឯកសារនេះទៅឲ្យមន្ត្រីអនុវត្តច្បាប់ សម្រាប់ផ្តល់សេវាកម្មដល់អ្នកចុងចោទក៏ដោយ ។

មន្ត្រីអនុវត្តច្បាប់ដែលយកឯកសារទៅឲ្យអ្នកចុងចោទ នឹងកត់ត្រាកាលបរិច្ឆេទ និងពេលវេលា ដែលអ្នកចុងចោទបានទទួលឯកសារនេះ ។ ត្រង់នេះគេហៅថា “ភស្តុតាងនៃការផ្តល់សេវាកម្ម” ។ ភស្តុតាងនៃការផ្តល់សេវាកម្ម មានសារៈសំខាន់ ដោយសារតុលាការ នឹងមិនធ្វើសវនាការសម្រេចឡើយ បើតុលាការ មិនមានភស្តុតាងណាមួយបញ្ជាក់ថា អ្នកចុងចោទបានទទួលសេចក្តីជូនដំណឹងជាផ្លូវការអំពីសំណុំរឿងពាក់ព័ន្ធនឹងខ្លួនទេនោះ ។

អ្នកអាចតាមដានជាមួយនាយកដ្ឋាននគរបាល ឬការិយាល័យនគរបាលតំបន់ ដើម្បីសួរនាំថាតើអ្នកចុងចោទ បានទទួលដំណឹងអំពីសំណុំរឿងនៅពេលណា ។ អ្នកត្រូវកត់ត្រាព័ត៌មាននេះទុក សម្រាប់ប្រើនៅក្នុងសវនាការសម្រេច ។

## តើអ្នកចុងចោទ នឹងទទួលឯកសារតុលាការអ្វីខ្លះ?

អ្នកចុងចោទនឹងទទួលបាន ***ដីការកោះហៅ**/ ដីការរក្សាការពារ (PA-004)* ដែលផ្តល់ដំណឹងដល់អ្នកចុងចោទថាតើសវនាការសម្រេចនឹងត្រូវធ្វើឡើងនៅទីណា និងនៅពេលណា ។

អ្នកចុងចោទក៏នឹងទទួលបានសំណៅនៃ *បណ្តឹង* របស់អ្នកដែរ ហើយបើតុលាការចេញឲ្យ អ្នកចុងចោទក៏នឹងទទួលបាន ដីការរក្សាការពារបណ្តោះអាសន្នផងដែរ ។

## តើដីការក្សាការពារបណ្តោះអាសន្ន ចូលជាធរមាននៅពេលណា?

ដីការក្សាការពារបណ្តោះអាសន្ន ចូលជាធរមានភ្លាមៗ ក្រោយពេលចៅក្រមបានចុះហត្ថលេខារួចរាល់ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អ្នកចុងចោទត្រូវទទួលបានការជូនដំណឹងជាក់ស្តែងអំពី ដីការក្សាការពារបណ្តោះអាសន្នរបស់តុលាការ ឬក៏បានទទួល ដីការក្សាការពារបណ្តោះអាសន្នជាមុន ទើបអាចចោទអ្នកចុងចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មពីការប្រព្រឹត្តល្មើសនឹងដីកានេះ ។

## 11. តើសវនាការសម្រេច នឹងត្រូវធ្វើឡើងនៅពេលណា ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន?

មិនថាចៅក្រមបានចេញ ដីការក្សាការពារបណ្តោះអាសន្ន ឬមិនបានក៏ដោយ (បើអ្នកបានស្នើសុំតុលាការ) ក៏សំណុំរឿងរបស់អ្នក នឹងត្រូវគ្រោងពេលសវនាការ**សម្រេច**ក្នុងរវាង 21 ថ្ងៃ បើអ្នកមិនបានដកពាក្យបណ្តឹងមកវិញទេនោះ ។

បើអ្នកបានដកសំណុំរឿងមកវិញ (លុបចោល**ដោយមិនបាច់មានការធ្វើបុរេនិច្ឆ័យ**) គឺអ្នកអាចដាក់ពាក្យប្តឹងឡើងវិញបាននៅពេលក្រោយ ។

## 12.សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកចុងចោទ ក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន ។ សិទ្ធិរបស់អ្នក ក្នុងនាមជាអ្នកចុងចោទ

បើអ្នកជាចុងចោទ នៅក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន អ្នកមានសិទ្ធិដើម្បី ៖

- ទទួលបានសំណៅថតចម្លងនៃ *ពាក្យបណ្តឹង*ដែលដាក់ប្តឹងក្នុងសំណុំរឿង
- ទទួលបានការជូនដំណឹងអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងចំពោះសវនាការសម្រេច
- ដាក់ស្នើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ចំពោះបណ្តឹងរបស់ *ដើមចោទ*(មិនមែនជាភាពតម្រូវ)

- ចូលរួមសវនាការសម្រេច និងបង្ហាញភ័ស្តុតាងរបស់ខ្លួន រួមទាំងការធ្វើកសិណសាក្សី និងហៅសាក្សី ដើម្បីគាំទ្រសំណុំរឿងរបស់អ្នក
- ស្នើសុំឲ្យការិយាល័យក្រឡាបញ្ជីចេញដីកាកោះហៅសាក្សីដើម្បីមកបង្ហាញខ្លួនក្នុងសវនាការ បើជាការចាំបាច់ ដើម្បីធានាបានថាសាក្សីនឹងមកបង្ហាញខ្លួនក្នុងសវនាការ ។
- ស្នើសុំឲ្យតុលាការកែប្រែ(ប្តូរឬរំលាយ(លុបចោល) នូវដីការក្សាការពារបណ្តោះអាសន្ន និង
- ជួលមេធាវី ឬស្វែងរកជំនួយការផ្សេងទៀត ដើម្បីឆ្លើយតបការចោទប្រកាន់ ឬរៀបចំការរក្សាការពារខ្លួន ។ ព័ត៌មានអំពីធនធានច្បាប់ មានបង្ហាញនៅលើក្របខាងក្រោយនៃសៀវភៅគោលការណ៍ណែនាំនេះ ។

## ការទទួលខុសត្រូវរបស់អ្នក ក្នុងនាមជាអ្នកចុងចោទ

បើអ្នកជាអ្នកចុងចោទ នៅក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន ហើយអ្នកទទួលបានដីការក្សាការពារបណ្តោះអាសន្ន អ្នកត្រូវធ្វើតាមគ្រប់ចំណុចទាំងអស់របស់ ដីកានេះ ក្នុងពេលដែលវានៅមានប្រសិទ្ធភាព ។ ប្រសិនបើអ្នកមិនធ្វើតាមល័ក្ខខ័ណ្ឌក្នុងដីកាតុលាការទេ គេនឹងចាប់ខ្លួនអ្នក ដោយចោទប្រកាន់ពីការប្រព្រឹត្តិឧក្រិដ្ឋកម្ម ។

មានតែចៅក្រមទេដែលអាចផ្លាស់ប្តូរល័ក្ខខ័ណ្ឌនៃដីការក្សាការពារបណ្តោះអាសន្ន បាន ។ អ្នកដើមចោទមិនអាចផ្លាស់ប្តូរល័ក្ខខណ្ឌ ឬ ឲ្យអ្នកប្រព្រឹត្តិបំពានល័ក្ខខ័ណ្ឌរបស់វាបានឡើយ ។ ឧទាហរណ៍ ប្រសិនបើសេចក្តីក្នុងដីការក្សាការពារបណ្តោះ

អាសន្ន ហាមឃាត់អ្នក មិនឲ្យចូលក្នុងផ្ទះដែលអ្នកបានរស់នៅរួមគ្នាជាមួយអ្នកដើមចោទ អ្នកនឹងត្រូវរងការចោទប្រកាន់ពីការប្រព្រឹត្តិបទឧក្រិដ្ឋ បើអ្នកចូលក្នុងផ្ទះនោះក្តី បើទោះបីជាអ្នកដើមចោទបានអញ្ជើញអ្នកឲ្យចូលក្តី ។ ការបំពានលើខ្លឹមសារនៃដីការក្សាការពារបណ្តោះអាសន្នគឺជាបទឧក្រិដ្ឋចំណាត់ថ្នាក់ D ដែលត្រូវមានទោសជាប់គុករហូតដល់ 364 ថ្ងៃ និង/ឬត្រូវពិន័យជាប្រាក់រហូតដល់ $2,000 ។

## ស្នើសុំកែប្រែ ឬរំលាយដីការក្សាការពារបណ្តោះអាសន្ន

បើអ្នកចង់ឲ្យតុលាការកែប្រែ ឬរំលាយដីការក្សាការពារបណ្តោះអាសន្នចោល សូមប្រើទម្រង់ ៖ *ញត្តិ**របស់អ្នកចុងចោទ**ដើម្បីរំលាយដីកាបណ្តោះអាសន្នដើម្បីការរក្សាការពារ ឬញត្តិស្នើសុំកែប្រែ/កែសម្រួលដីការក្សាការពារ (PA-010 )*។

- ទម្រង់*PA-010* មានផ្តល់ជូនអនឡាញ ឬក៏អាចទៅយកបានពីការិយាល័យក្រឡាបញ្ជីនៃតុលាការមណ្ឌល ។ ទម្រង់អនឡាញអាចរកបាននៅឯ ៖ www.courts.maine.gov/fees_forms។

- ប្រសិនបើអ្នកមិនមានកុំព្យូទ័រ ឬម៉ាស៊ីនបោះពុម្ពប្រើទេ ហើយចង់បំពេញទម្រង់តាមអនឡាញ អ្នកអាចទៅបណ្ណាល័យណាមួយ ដែលមានបម្រើកុំព្យូទ័រសាធារណៈ ហើយសុំបណ្ណារក្សឲ្យជួយអ្នកស្វែងរកទម្រង់ដែលអ្នកចង់បំពេញអនឡាញ ។ ពេលអ្នកបំពេញទម្រង់នេះរួចហើយ សូមចុះហត្ថលេខានៅមុខសារការី មេធាវី ឬក្រឡាបញ្ជី ហើយដាក់ស្នើជាមួយនឹងតុលាការមណ្ឌល ។
- អ្នកមិនចាំបាច់បង់ថ្លៃ ចំពោះការដាក់ស្នើទម្រង់ PA-010 ឡើយ ។ អ្នកអាចបំពេញព័ត៌មានក្នុងទម្រង់នេះ ដោយដៃ ។
- ប្រសិនបើអ្នកស្នើសុំតុលាការឲ្យកែសម្រួល ឬ រំសាយដីការក្សាការពារបណ្ដោះអាសន្ន ត្រូវផ្ដល់ដំណឹងដល់អ្នកដើមចោទ ឲ្យបានដឹងជាមុនចំនួន 48 ម៉ោងអំពីសវនាការ ប្រសិនបើចៅក្រមមិនបានកំណត់ពេលសវនាការលឿនជាងនេះទេនោះ ។

មិនថាអ្នកដាក់ស្នើ ឬមិនដាក់ស្នើការឆ្លើយតបចំពោះការចោទប្រកាន់ជាលាយលក្ខណ៍អក្សរក៏ដោយ បើអ្នកចង់ប្រឆាំងនឹងការស្នើសុំរបស់ដើមចោទ អំពីដំណោះស្រាយ ឬបញ្ចេញយោបល់អំពីសំណុំរឿងនេះ គឺអ្នកត្រូវតែចូលរួមក្នុងសវនាការសម្រេច ។

ប្រសិនបើអ្នកមិនបានទទួលសេវាកម្មទេ (មិនបានទទួលសេចក្ដីជូនដំណឹងពីតុលាការ) នៅត្រឹមកាលបរិច្ឆេទសវនាការទេ តុលាការនឹងគ្រោងពេលថ្មីសម្រាប់ធ្វើសវនាការ នាពេលក្រោយ ។

ត្រូវប្រាប់ការិយាល័យក្រឡាបញ្ជីឲ្យដឹងជានិច្ច អំពីការផ្លាស់ប្ដូរអាសយដ្ឋាន ។ អ្នកអាចប្រើទម្រង់ *ការជូនដំណឹងអំពីការប្ដូរអាសយដ្ឋាន (CV/CR-199)* ចំពោះស្ថានភាពនេះ ។

## 13. ប្រសិនបើដីការក្សាការពារបណ្ដោះអាសន្នហាមឃាត់អ្នកចុងចោទមិនឲ្យមានអាវុធគ្រោះថ្នាក់ ក្នុងដៃ

ប្រសិនបើដីកាបណ្ដោះអាសន្នហាមឃាត់អ្នកមិនឲ្យកាន់កាប់ជាកម្មសិទ្ធិនូវកាំភ្លើង ឬអាវុធគ្រោះថ្នាក់ផ្សេងទៀត អ្នកត្រូវយកអាវុធតាមការរៀបរាប់ជាក់លាក់ មកប្រគល់ឲ្យមន្ត្រីអនុវត្តច្បាប់ ឬបុគ្គលផ្សេងទៀត ដូចដែលបានបញ្ជាក់ក្នុងដីកា ។

ប្រសិនបើដីកាអនុញ្ញាតឲ្យអ្នកប្រគល់របស់ជាក់លាក់ណាមួយ ទៅនរណាផ្សេងទៀតក្រៅពីមន្ត្រីអនុវត្តច្បាប់ ឬអ្នកត្រូវតែដាក់ស្នើសេចក្ដីថ្លែងការ បញ្ជាក់អត្តសញ្ញាណជននោះ ហើយត្រូវរាយមុខរបស់ទាំងអស់ដែលអ្នក យកមកប្រគល់ ឲ្យ

ជននោះ ផងដែរ ។ សេចក្ដីថ្លែងការណ៍ត្រូវតែដាក់ស្នើដល់តុលាការ ឬនាយកដ្ឋាននគរបាលប្រចាំមូលដ្ឋាន ឬការិយាល័យនគរបាលតំបន់ ឲ្យបានក្នុងរវាង 24 ម៉ោងនៃការប្រគល់របស់នោះ ទៅឲ្យបុគ្គលតាមសេចក្ដីក្នុង ដីកា ។ អ្នកត្រូវតែប្រគល់ កាំភ្លើង ឬ អាវុធគ្រោះថ្នាក់ឯទៀត ទៅតាមពេលវេលា ដូចមានចែងក្នុង ដីកា ។

## 14. ចំណុចដែលអ្នកត្រូវចងចាំ មុនការបើកសវនាការសម្រេច

ក្រឡាបញ្ជីនឹងគ្រោងពេលសម្រាប់ធ្វើសវនាការសម្រេចលើសំណុំរឿងការរក្សាការពារ ពីការរំលោភបំពាន ក្នុងរវាង 21 ថ្ងៃ គិតពីថ្ងៃនៃការដាក់ *ពាក្យបណ្ដឹង* ។

អ្នកចុងចោទ ត្រូវទទួលបានការជូនដំណឹងជាផ្លូវការ អំពីសំណុំរឿង (ទទួលដំណឹង) ទើបតុលាការអាចបើកសវនាការសម្រេចបាន ។ ប្រសិនបើអ្នកចុងចោទមិនបានទទួលសេវាកម្មត្រឹមកាលបរិច្ឆេទ បើកសវនាការ តុលាការនឹងគ្រោងពេលឡើងវិញ ដើម្បីបើកសវនាករនាពេលក្រោយ ។

ប្រសិនបើអ្នកចុងចោទមិនទាន់ទទួលបានសេវាកម្ម នៅត្រឹមកាលបរិច្ឆេទបើកសវនាការសម្រេចទេ អ្នកដើមចោទនៅតែអាចធ្វើដំណើរទៅកាន់តុលាការនៅក្នុងថ្ងៃនោះ ដើម្បីបញ្ជាក់ថាសំណុំរឿងនេះ មិនត្រូវបានទាត់ពាក្យបណ្ដឹងចោល ហើយក៏ដើម្បីបញ្ជាក់ផងដែរថា ដីការក្សាការពារ បណ្ដោះអាសន្នណាមួយ ដែលតុលាការបានចេញ នៅតែមានសុពលភាពដដែល ។

ភាគីទាំងពីរត្រូវតែទៅចូលរួមសវនាការសម្រេច បើមិនដូច្នេះទេ ចៅក្រមអាចនឹងសម្រេចសេចក្ដីឲ្យកំបាំងមុខឲ្យភាគីអវត្តមានជាអ្នកចាញ់ក្ដី ។ ប្រសិនបើអ្នកដើមចោទមិនទៅចូលរួមក្នុងសវនាការទេ ចៅក្រមអាចបោះបង់ចោលសំណុំរឿងនេះ ។ ប្រសិនបើសំណុំរឿងនេះត្រូវបានតុលាការបោះបង់ចោល ដីការក្សាការបណ្ដោះអាសន្នណាមួយដែលតុលាការបានចេញ ក៏អស់សុពលភាពដែរ ។

ប្រសិនអ្នកចុងចោទមិនទៅចូលរួមសវនាការទេ ចៅក្រមអាចចុះហត្ថលេខាលើដីការក្សាការពារសម្រេច ពីការរំលោភបំពាន ។

### ការស្នើសុំឲ្យពន្យារពេលធ្វើសវនាការ

ប្រសិនបើអ្នកដើមចោទ ឬ អ្នកចុងចោទ បានជួបប្រទះភាពអាសន្ន និងមិនអាចចូលរួមក្នុងសវនាការបាន ទៅតាមកាលបរិច្ឆេទដែលបានគ្រោងពេលទុក ភាគីនោះ ត្រូវតែជម្រាបតុលាការឲ្យដឹងជាប្រញាប់ ហើយស្នើសុំ **ការបន្ត** (ការផ្អាក) សវនាការជាលាយលក្ខណ៍អក្សរ ។ តុលាការនឹងសម្រេចថាតើត្រូវផ្ដល់តាមសំណើសុំបន្តធ្វើសវនាការនាពេលក្រោយដែរឬទេ ។

## 15. ដីកាដោយមានការយល់ព្រម (ដោយមិនមានសវនាការ)

មុននឹងចាប់ផ្ដើមបើកសវនាការសម្រេច តុលាការអាចសួរនាំគូភាគីក្នុងវិវាទថាតើពួកគេយល់ព្រមគិតពិចារណាក្នុងការដាក់ចូលក្នុងដីការក្សាការពារដោយការយល់ព្រមជាជាងមានសវនាការពេញលេញ ។

ដីកាដោយមានការយល់ព្រម តែងធ្វើឡើង ក្រោយពេលចៅក្រមពិភាក្សាជាមួយគូភាគីទាំងអស់នៅក្នុងតុលាការ ឬក៏តាមរយៈអ្នកកណ្ដាលដូចជាក្រុមតស៊ូមតិប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ឬមេធាវី ។ ប្រសិនបើតុលាការចេញដីការក្សាការពារបណ្ដោះអាសន្ន ដោយហាមមិនឲ្យមានការទាក់ទងគ្នា

រវាងអ្នកដើមចោទ និងអ្នកចុងចោទ ករណីនេះ គឺមិនត្រូវមានការពិភាក្សាគ្នាដោយផ្ទាល់ ឬការទាក់ទងរវាងភាគីទាំងពីរ ដោយមិនមានវត្តមានរបស់ចៅក្រមឡើយ ។

ដីការក្សាការពារដោយមានការយល់ព្រមអាចមានរួមបញ្ចូលការរក្សាការពារដូចគ្នា ហើយមានឥទ្ធិផ្លូវច្បាប់ *ដូចគ្នា* ចំពោះដីការក្សាការពារដែលតុលាការចេញ ក្រោយពីធ្វើសវនាការរួចរាល់ដែរ ។ អ្នកចុងចោទនឹងត្រូវចាប់ខ្លួន យកមកកាត់ទោស ចំពោះការបំពានលើដីការក្សាការពារដោយមានការយល់ព្រម ដូចជាគេនឹងអ្វីដែលខ្លួនអាចប្រព្រឹត្តិបំពាន ចំពោះដីការក្សាការពារដែលតុលាការចេញក្រោយការធ្វើសវនាការដែរ ។

ទោះជាយ៉ាងណាក៏ដោយដីកាដោយមានការយល់ព្រម ត្រូវបានចេញដោយចៅក្រម ដោយមិនបាច់រកឃើញការពិត ដែលថាអ្នកចុងចោទបានរំលោភបំពាន រំលោភផ្លូវភេទ ជួញដូរផ្លូវភេទ ឈ្លបមើល ឬចែកចាយរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែង ។

## 16. តើនឹងមានអ្វីកើតឡើងក្នុងសវនាការសម្រេច ?

សវនាការសម្រេចគឺធ្វើឡើងដោយសាធារណៈ និងធ្វើឡើងនៅចំពោះមុខចៅក្រម ។

### ការបង្ហាញសំណុំរឿង

គឺដូចគ្នាទៅនឹងសំណុំរឿងរដ្ឋប្បវេណីឯទៀតដែរ អ្នកដើមចោទជាអ្នកឡើងមុន និងបង្ហាញភ័ស្តុតាង ចំពោះការចោទប្រកាន់ក្នុង *បណ្តឹង* ។

អ្នកចុងចោទនឹងមានឱកាសឡើងការពារខ្លួន ក្រោយអ្នកដើមចោទបញ្ចប់ការបង្ហាញសំណុំរឿងក្នុងបណ្តឹង ។

អ្នកដើមចោទនឹងស្នើសុំតុលាការឲ្យចេញដំណោះស្រាយជាក់លាក់ ចំពោះ *បណ្តឹង* ។ សូមមើលផ្នែក ក.17 ។ អ្នកចុងចោទ ត្រូវត្រៀមខ្លួនឲ្យបានរួចរាល់ដើម្បីពន្យល់ថាហេតុអ្វីតុលាការមិនត្រូវធ្វើតាមដំណោះស្រាយដែលភាគីដើមចោទបានស្នើសុំ ឬក៏ស្នើសុំដំណោះស្រាយផ្សេងពីនេះ ។ ប្រសិនបើអ្នកចុងចោទជឿថា សំណុំរឿងរបស់អ្នកដើមចោទ បានប្តឹងដោយប្រាសចាកពីមូលដ្ឋានការពិត អ្នកចុងចោទ ត្រូវត្រៀមខ្លួន បង្ហាញភ័ស្តុតាងអំពីរឿងនេះ ។

ទាំងអ្នកដើមចោទ និង អ្នកចុងចោទត្រូវតែត្រៀមខ្លួនរួចរាល់ ដើម្បីបង្ហាញភ័ស្តុតាង យកជាកសិណ ហើយបើចាំបាច់ ហៅសាក្សីមកក្នុងសវនាការ ។

បន្ថែមពីលើគូភាគីក្នុងវិវាទ បុគ្គលដែលបានដឹងច្បាស់អំពីសាច់រឿងនេះអាចឡើងធ្វើកសិណ ផងដែរ ។ បើសំណុំរឿងនេះ ត្រូវបានប្តឹងតាងនាមឲ្យកុមារ អាយុក្រោម 18 ឆ្នាំ តុលាការអាចតម្រូវឲ្យក្មេងរូបនោះមកធ្វើជាកសិណ លើកលែងតែអ្នកដើមចោទ ឬសាក្សីផ្សេងទៀត បានដឹងច្បាស់ថារឿងហេតុបានកើតឡើងដូចម្តេច ហើយអាចធ្វើកសិណជំនួសកុមារនោះបាន ។

ដូចគ្នាទៅនឹងសំណុំរឿងរដ្ឋប្បវេណីឯទៀតដែរ សវនាការសម្រេចគឺត្រូវស្ថិតនៅក្រោមច្បាប់វិន័យភស្តុតាងរបស់រដ្ឋមេន ដែលដាក់កម្រិតចំពោះប្រភេទព័ត៌មាន ដែលចៅក្រមត្រូវយកមកពិចារណា ។ តុលាការនឹងសម្រេចទៅតាមការជំទាស់ណាមួយ ។

## នរណាខ្លះអាចត្រូវចូលរួមសវនាការ?

គូភាគីក្នុងវិវាទ អាចត្រូវបានរួមកំដរដោយមិត្ត និងសមាជិកគ្រួសារ និងមានអ្នកតស៊ូមតិ ឬមេធាវីជាអ្នកជួយ នៅក្នុងសវនាការ ។ អ្នកគាំទ្រមិនអាចយកជាកស្មីណបានទេ បើខ្លួនមិនបានដឹងដោយផ្ទាល់អំពីហេតុការណ៍ក្នុង *បណ្តឹង*ទេនោះ ។

## បើគូភាគី គឺជាឪពុកម្តាយរបស់កុមារអនីតិជន

ប្រសិនបើអ្នកដើមចោទ និង អ្នកចុងចោទ គឺជាឪពុកម្តាយនៃកុមារអនីតិជន ភាគីទាំងពីរត្រូវតែយកលិខិតថ្លែងសច្ចារអំពីការផ្តល់ប្រាក់ឧបត្ថម្ភកូន (FM-050) បំពេញរួចហើយ មកកាន់សវនាការសម្រេច ប្រសិនបើដីកាផ្តល់ប្រាក់ឧបត្ថម្ភកូន តុលាការមិនទាន់បានចេញឲ្យនៅឡើយ ។ ចៅក្រមអាចសួរនាំអំពីប្រាក់ចំណូល ។ ប្រសិនបើតុលាការចេញដីកា ចៅក្រមអាចចាត់ចែងការបង់ប្រាក់ឧបត្ថម្ភកូន ។ ប្រសិនបើគ្មានដីកាបង្គាប់ការបង់ប្រាក់ឧបត្ថម្ភកូននៅមិនទាន់បានចេញឲ្យអនុវត្តនៅឡើយ ។

## 17. តើដំណោះស្រាយអ្វីខ្លះដែលអាចមានរួមក្នុងដីការក្សាការពារពីការរំលោភបំពាន?

ដីកាសម្រាប់ការរក្សាការពារពីការរំលោភបំពានអាចរួមមានចំណុចមួយ ឬច្រើន ដូចតទៅ ៖

1. អ្នកចុងចោទមិនត្រូវធ្វើឲ្យមានការឈឺចាប់ គម្រាមកំហែង ឬបង្កភាពរំខានចំពោះអ្នកដើមចោទ និងកូនណាមួយ ដែលរស់នៅក្នុងផ្ទះរបស់អ្នកដើមចោទ ។
2. អ្នកចុងចោទមិនត្រូវមានការទាក់ទង **ដោយផ្ទាល់** ឬ **ប្រយោល** ជាមួយអ្នកដើមចោទឡើយ
3. អ្នកចុងចោទត្រូវនៅឲ្យឆ្ងាយពីផ្ទះ សាលា កន្លែងប្រកបរបររកស៊ី ឬកន្លែងធ្វើការរបស់អ្នកដើមចោទ
4. អ្នកចុងចោទមិនត្រូវលបតាម ឬ ដើរតាមអ្នកដើមចោទឡើយ
5. អ្នកចុងចោទមិនត្រូវមានកាំភ្លើង ឬអាវុធគ្រោះថ្នាក់ផ្សេងទៀត ជាកម្មសិទ្ធិឡើយ
6. អ្នកដើមចោទមិនត្រូវយក លក់ ធ្វើឲ្យខូចខាត ឬបំផ្លាញទ្រព្យសម្បត្តិណាមួយដែលជារបស់អ្នកដើមចោទ ទាំងមូល ឬជាផ្នែកឡើយ
7. អ្នកចុងចោទមិនត្រូវធ្វើឲ្យរបួស ឬ គម្រាមកំហែងដើម្បីឲ្យរបួសដល់សត្វជាកម្មសិទ្ធិ ឬសត្វដែលបានរក្សាទុក ដោយភាគីណាមួយឡើយ

8. អ្នកចុងចោទមិនត្រូវចែកចាយរូបភាពឯកជនរបស់អ្នកដើមចោទ ដែលមានភាពអាសអាភាសជាក់ស្តែង និង

9. អ្នកចុងចោទមិនត្រូវបំផ្លាញ ផ្ទេរ ឬផ្លាស់ប្តូរ ចំពោះលិខិតឆ្លងដែនឬឯកសារនៃការអន្តោប្រវេសន៍ឯទៀតរបស់អ្នកដើមចោទ ដែលនៅក្នុងដៃរបស់ខ្លួន ឡើយ ។

គ្រប់ដីកាតុលាការ ក៏អាចរួមបញ្ចូល ចំណុចទាំងនេះផងដែរ ៖

1. ផ្តល់ឲ្យអ្នកដើមចោទ ឬអ្នកចុងចោទ នូវកម្មសិទ្ធិបណ្តោះអាសន្នចំពោះផ្ទះ

2. ផ្តល់ឲ្យមានការបែងចែកទ្រព្យសម្បត្តិផ្ទាល់ខ្លួន

3. ផ្តល់សិទ្ធិថែទាំ គ្រប់គ្រង ឬថែរក្សាសត្វណាមួយដែលជាកម្មសិទ្ធិ ឬដែលបានរក្សាទុក ដោយភាគីណាមួយ ឬជាកម្មសិទ្ធិ ដែលបានរក្សាទុក ដោយកុមារអនីតិជន ដែលរស់នៅក្នុងគ្រួសារ

4. តម្រូវឲ្យអ្នកចុងចោទ បង់ប្រាក់ឧបត្ថម្ភបណ្តោះអាសន្នដល់អ្នកដើមចោទ ដោយសារការបាត់បង់ប្រាក់ចំណូល ការខូចខាតទ្រព្យសម្បត្តិ ឬថ្លៃចំណាយលើការរើលំនៅដ្ឋាន

5. តម្រូវឲ្យផ្តាច់ការធានារ៉ាប់រងជីវិត ដែលស្ថិតក្រោមឈ្មោះរបស់អ្នកចុងចោទ ក្នុងការទិញធានារ៉ាប់រងឲ្យអ្នកដើមចោទ ដោយត្រូវយកសំណៅនៃដីកាតុលាការ ទៅប្រគល់ឲ្យក្រុមហ៊ុនធានារ៉ាប់រងផងដែរ

6. តម្រូវឲ្យអ្នកចុងចោទទទួលការពិគ្រោះយោបល់ ឬចូលរួមក្នុងកម្មវិធីអន្តរាគមន៍អ្នកវាយដំ ដែលមានអាជ្ញាប័ណ្ណបញ្ជាក់ត្រឹមត្រូវ

7. តម្រូវឲ្យអ្នកចុងចោទលុបចេញ បំផ្លាញចោល ឬប្រគល់ទៅអ្នកដើមចោទវិញនូវរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែង ឬត្រូវបង់ថ្លៃចំពោះការលុបចោល ការបំផ្លាញចោល ឬការប្រគល់ត្រឡប់វិញនូវរូបភាពទាំងនេះ ទៅឲ្យអ្នកដើមចោទ និង

8. បង់ថ្លៃការខូចខាតទាំងអស់ដែលពាក់ព័ន្ធនឹងការប្រគល់ត្រឡប់វិញ ឬថ្លៃការធ្វើឲ្យដូចដើមវិញ នៃលិខិតឆ្លងដែន ឬឯកសារអន្តោប្រវេ-សន៍ឯទៀតរបស់អ្នកដើមចោទ និងបង់បំណុលណាមួយរបស់អ្នកដើមចោទ ដែលកើតឡើងពីទំនាក់ទំនងការជួញដូរផ្លូវភេទ ។

ប្រសិនបើអ្នកចុងចោទ និងអ្នកដើមចោទមានកូនរួមគ្នា នៅក្នុងដីកាអាចមានរួមបញ្ចូលចំណុចណាមួយ ខាងក្រោម ៖

1. ផ្តល់សិទ្ធិជាឪពុកម្តាយបណ្តោះអាសន្ន (កន្លែងរស់នៅចម្បង និងការមកលេង)

2. បង្គាប់ឲ្យបង់ប្រាក់ឧបត្ថម្ភកូន រួមទាំងការកាត់ប្រាក់ខែទុកភ្លាមៗ ដើម្បីប្រមូលប្រាក់សម្រាប់ឧបត្ថម្ភកូន និង

3. បង្គាប់ឲ្យដាក់ពាក្យចំពោះលិខិតថ្លែងសច្ចារប្រាក់ឧបត្ថម្ភកូន ប្រសិនបើមិនទាន់បានធ្វើនៅឡើយ ។

ចៅក្រមអាចបង្គាប់ឲ្យអ្នកចុងចោទបង់ថ្លៃតុលាការ និង/ឬប្រាក់កម្រៃមេធាវីផងដែរ ។

ចំពោះដីកាផ្សេងទៀត ចៅក្រមអាចបង្គាប់ឲ្យអ្នកដើមចោទបង់ថ្លៃតុលាការ និង/ឬប្រាក់កម្រៃមេធាវី ។ ស្ថានភាពនេះ អាចកើតឡើងតែក្នុងករណីដែលអ្នកដើមចោទបានចាញ់ក្តី ហើយតុលាការសម្រេចថាបណ្តឹងរបស់អ្នក *មិនសមហេតុផល* ។

ដីកា អាចបញ្ជាក់អំពីដំណោះស្រាយណាមួយ ដែលមានភាពចាំបាច់ និងសមរម្យ ។

អាស្រ័យលើលទ្ធផលជាក់លាក់ អំពីអង្គហេតុក្នុងដីកាសម្រេច តុលាការអាចហាមឃាត់អ្នកចុងចោទ មិនឲ្យមានជាកម្មសិទ្ធិ មិនឲ្យទទួល ឬមិនឲ្យមានក្នុងដៃនូវកាំភ្លើងឬគ្រាប់រំសេវក្រោមច្បាប់សហព័ន្ធបើទោះបីជាក្រោមច្បាប់របស់រដ្ឋមេន មិនបានហាមឃាត់ អ្នកចុងចោទមិនឲ្យធ្វើជាកម្មសិទ្ធិចំពោះកាំភ្លើង ឬអាវុធគ្រោះថ្នាក់ ក៏ដោយ ។ សូមមើលផ្នែក ក.9 ។

## 18. តើដីការក្សាការពារសម្រេចពីការរំលោភបំពានមានប្រសិទ្ធភាពយូរប៉ុណ្ណា ?

រហូតដល់ពីរ (2) ឆ្នាំ ។ ចៅក្រមអាចចេញដីកាមានរយៈពេលខ្លីជាងនេះ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមការយល់ព្រមរបស់គូភាគីក្នុងវិវាទ ។

## 19. តើត្រូវធ្វើដូចម្តេច បើអ្នកចុងចោទប្រព្រឹត្តបំពានដីកាតុលាការ ?

អ្នកដើមចោទត្រូវហៅទូរស័ព្ទទៅប៉ុស្តិ៍នគរបាល ថាអ្នកចុងចោទបានប្រព្រឹត្តិរំលោភដីការក្សាការពារពីការរំលោភបំពាន (ដីការក្សាការពារណ្តោះអាសន្ន ឬសម្រេច) ។

សូមទូរស័ព្ទទៅលេខ 911 ប្រសិនបើមាននរណាម្នាក់ កំពុងតែស្ថិតក្នុងភាពគ្រោះថ្នាក់ភ្លាមៗ ។

អាស្រ័យលើលក្ខខណ្ឌជាក់លាក់របស់ដីការក្សាការពារពីតុលាការ អ្នកចុងចោទអាចមានកំហុសចំពោះបទឧក្រិដ្ឋចំណាត់ថ្នាក់ D ឬចំណាត់ថ្នាក់ C ហើយអាចត្រូវចាប់ខ្លួន ឬរងការពិន័យ ។

ចំពោះការចាប់ខ្លួនអ្នកចុងចោទ មន្ត្រីនគរបាល មិនចាំបាច់ឃើញផ្ទាល់ អំពីការបំពានចំពោះដីកាតុលាការ ឡើយ ។

## 20. ការប្តូរ ឬការបញ្ចប់ដីការក្សាការពារសម្រេច

គឺមានតែ ចៅក្រមប៉ុណ្ណោះដែលអាចកែប្រែ (ប្តូរ) បញ្ចប់ (ផ្តាច់) ឬបន្តសុពលភាព ដីការក្សាការពារ បើទោះបីជាគូភាគីក្នុងវិវាទបានដូរគំនិតអំពីលក្ខខណ្ឌ ឬបានព្រមព្រៀងគ្នា អ្វីមួយក៏ដោយ ។ បើចៅក្រមនៅមិនទាន់បានធ្វើដូច្នេះទេ ដីកាច្បាប់ដើម នឹងនៅមានប្រសិទ្ធភាពដដែល

។ ការបំពានណាមួយនឹងធ្វើឲ្យអ្នកចុងចោទស្ថិតក្នុងហានិភ័យពីការចាប់ខ្លួន ឬរងការកាត់ទោស ។

ដើម្បីកែសម្រួលដីកា មុនវាចប់សុពលភាពគូភាគីក្នុងវិវាទ ត្រូវដាក់ការស្នើសុំកែសម្រួល ជាលាយលក្ខណ៍អក្សរ (ញត្តិ) ទៅកាន់ក្រឡាបញ្ជីតុលាការមណ្ឌល ។

អ្នកដើមចោទ ៖ ប្រើ *ញត្តិក្រោយការវិនិច្ឆ័យដើម្បីសុំកែប្រែ/ញត្តិស្នើសុំការបញ្ចប់ដីការក្សាការពារ (PA-022 )*របស់អ្នកដើមចោទ ។ អ្នកចុងចោទ ៖ ប្រើប្រាស់ *ញត្តិរបស់អ្នកចុងចោទដើម្បីរំលាយដីការក្សាការពារបណ្ដោះអាសន្ន ឬដើម្បីកែសម្រួល/កែប្រែ (ដោយមានដាក់បញ្ចូលនូវលិខិតថ្លែងសច្ចារ)* (*PA-010*) ។

ក្រឡាបញ្ជីនឹងប្រាប់ពីកាលបរិច្ឆេទនិងពេលវេលាសវនាការ និងរៀបចំសេវាកម្ម តាមប្រៃសណីយ៍ ឬដោយក្រុមអនុវត្តច្បាប់ ។

ដំណើរការទូទៅមានភាពដូចគ្នា សម្រាប់ប្រើចំពោះញត្តិស្នើសុំកែប្រែដីការក្សាការពារ ដូចបានរៀបរាប់ក្នុងផ្នែក ក.10-ក.16 ។

## 21. តើត្រូវធ្វើដូចម្ដេច បើអ្នកដើមចោទចង់ពន្យាសុពលភាពនៃដីការក្សាការពារ

ដីការក្សាការពារពីការរំលោភបំពានអាចមានប្រសិទ្ធភាពរហូតដល់ពីរ (2) ឆ្នាំ ។ បើអ្នកដើមចោទ ចង់ឲ្យដីកានេះ ស្ថិតនៅក្នុងរយៈពេលយូរ អ្នកដើមចោទត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរ មកកាន់ក្រឡាបញ្ជីតុលាការមណ្ឌល ។ ប្រើទម្រង់ *ញត្តិស្នើសុំពន្យារពេលផុតកំណត់ដីការក្សាការពារ (PA-013 )* ។

អ្នកដើមចោទត្រូវតែដាក់ពាក្យស្នើសុំពន្យារសុពលភាពដីការក្សាការពារឲ្យបានចំនួន 30 ថ្ងៃ មុនកាលបរិច្ឆេទហួសកំណត់ ចូលមកដល់ ដើម្បីបង្ការនូវចន្លោះក្នុងការរក្សាការពារ ។ បើដើមចោទមិនបានដាក់ពាក្យស្នើសុំពន្យារពេលផុតកំណត់នៃដីការក្សាការពារទេ ដីការក្សាការពារច្បាប់ដើមនៅដដែល មានប្រសិទ្ធភាព រហូតដល់ថ្ងៃផុតកំណត់ ។ បើអ្នកដើមចោទ មិនបានដាក់*ញត្តិស្នើសុំពន្យារពេលផុតកំណត់នៃដីការក្សាការពារ*ឲ្យបានត្រឹមថ្ងៃផុតកំណត់ទេ ហើយនៅតែត្រូវការការរក្សាការពារបន្តទៅមុខទៀត ដើមចោទត្រូវដាក់ *បណ្ដឹង*សារថ្មី ដែលនិយាយអំពីការចោទប្រកាន់អំពីការរំលោភបំពានថ្មីទៀត

ប្រើដំណើរការទូទៅដូចគ្នា ចំពោះការដាក់ញត្តិសុំពន្យារដីការក្សាការពារ ដូចបានរៀបរាប់ក្នុងផ្នែក ក.10-ក.16 ។ អ្នកចុងចោទមានសិទ្ធិដើម្បីឆ្លើយតបការស្នើសុំនេះ ដោយការទៅចូលរួមសវនាការលើញត្តិដើម្បីបន្តសុពលភាពដីការក្សាការពារ និង/ឬ ដោយការដាក់ញត្តិរបស់ខ្លួន ដើម្បីស្នើសុំការកែសម្រួល រំលាយ ឬ កែប្រែដីការក្សាការពារ (សូមមើលទម្រង់ *PA-010*) ។

## 22. ដីការក្សាការពារពីការរំលោភបំពាន ដែលចេញដោយតុលាការនៅរដ្ឋផ្សេង

បើអ្នកទទួលបានដីការក្សាបណ្តោះអាសន្ន ឬសម្រេចពីការរំលោភបំពាន ដែលចេញដោយតុលាការនៅរដ្ឋផ្សេង អ្នកអាចដាក់ពាក្យប្រាប់ ឬ “ចុះបញ្ជី” នូវដីការក្សាការពារនោះ ជាមួយនឹងតុលាការមណ្ឌលរបស់រដ្ឋមេន ។ អ្នកមិនចាំបាច់ចុះបញ្ជីដីការក្សាការពារ ពីរដ្ឋផ្សេង ដើម្បីឲ្យដីកានោះ ត្រូវបានអនុវត្តនៅរដ្ឋមេនឡើយ តែការចុះបញ្ជីវាអាចជួយដល់មន្ត្រីអនុវត្តច្បាប់ ក្នុងការអនុវត្តដីកានេះ ។ ដីកាចេញពីរដ្ឋផ្សេង ជួនកាលត្រូវបានហៅថាជា “សាលក្រមមកពីក្រៅ” ។

ដើម្បីចុះបញ្ជីដីកា អ្នកត្រូវផ្តល់សំណៅថតចម្លងពិតនៃដីការក្សាការពារបណ្តោះអាសន្ន ឬ សម្រេចពីរដ្ឋផ្សេងទៀត ទៅការិយាល័យក្រឡាបញ្ជីតុលាការមណ្ឌល ក្នុងខោនធីដែលលោកអ្នករស់នៅ ។ រក្សាទុកសំណៅមយួច្បាប់នៃដីការក្សាការពារមួយសន្លឹកសម្រាប់ជាឯកសាររបស់អ្នក ។

អ្នកចុងចោទ នឹងទទួលបានសេចក្តីជូនដំណឹងអំពីដីការក្សាការពារបណ្តោះអាសន្ន ឬសម្រេចពីតុលាការនៅរដ្ឋផ្សេង ហើយនឹងមិនប្រាប់ឲ្យបានដឹងឡើយថា អ្នកបាន ចុះបញ្ជីដីកានេះ ។

នៅពេលដែលសំណៅថតចម្លងពិតនៃដីការក្សាការពាររបស់អ្នក ត្រូវបានចុះបញ្ជីរួចហើយ ដីកានោះ នឹងមានស្ថានទម្ងន់ដូចគ្នា នឹងដីកាច្បាប់ដើម ដែលចេញដោយតុលាការរដ្ឋមេន ដែរ ។

# ផ្នែក ខ៖ ការរក្សាការពារពីការរុកគួន

## 1. តើការរុកគួនគឺជាអ្វី?

- អំពើបី (3) ឬច្រើនជាងនេះ អំពីបំភិតបំភ័យ ការប្រឈមមុខដាក់គ្នា ការប្រើកម្លាំងកាយជាក់ស្តែង ឬការគម្រាមប្រើកម្លាំងកាយ ពីសំណាក់អ្នកចុងចោទ ដែលធ្វើឡើងដោយមានបំណងធ្វើឲ្យអ្នកដើមចោទខ្លាច បំភ័យ ឬបង្កការខូចខាតចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយដែលការពិត អាកប្បកិរិយាបែបនេះ គឺពិតជាបង្កឲ្យមានការខ្លាច ការភ័យ ឬការខូចខាតទ្រព្យសម្បត្តិ អ្នកដើមចោទ ពិតមែន ឬ
- អំពី ឬ ការស្តែងចេញនៃអាកប្បកិរិយា ដែលបង្កបានជាអំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដូចជាការរំលោភផ្លូវភេទ ភេរវកម្ម ការចាប់ជំរិត ការវាយតប់យ៉ាងឃោឃៅ ការបង្កអគ្គីភ័យ ឬការបំពានភាពឯកជន ឬ
- ការបំពាន ឬការជ្រៀតជ្រែក ចំពោះសិទ្ធិរដ្ឋធម្មនុញ្ញ ឬសិទ្ធិពលរដ្ឋរបស់អ្នកដើមចោទ ។

## 2. នរណាអាចស្នើសុំការរក្សាការពារពីតុលាការ លើសំណុំរឿងការរុកគួន?

- ជនណាម្នាក់ រួមទាំងអ្នកទាំងអស់ដែលមានរាយក្នុងផ្នែក ក.2 និង
- អាជីវកម្ម ។

## 3. តើនរណាជាអ្នកចុងចោទក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន?

- នរណាក៏អាចជាអ្នកចុងចោទក្នុងសំណុំរឿងការរក្សាការពារពីការរុកគួនដែរ ។ ក្នុងន័យនេះ គឺមិនចាំបាច់មានទំនាក់ទំនងពិសេសរវាងអ្នកដើមចោទ និងអ្នកចុងចោទ ឡើយ ។
- ប្រសិនបើនរណាដែលធ្លាប់មាន ឬកំពុងតែមានទំនាក់ទំនង ជាមួយអ្នកបានរំលោភបំពានអ្នក លោកអ្នកអាចដាក់ពាក្យ *ប្តឹងស្នើសុំការរក្សាការពារពីការរំលោភបំពាន* (*PA-001*) ។ សូមមើលផ្នែក ក នៃសៀវភៅគោលការណ៍ណែនាំនេះ ។

## 4. តើសំណុំរឿងការរក្សាការពារពីការរុកគួនត្រូវចាប់ផ្តើមយ៉ាងដូចម្តេច? ទទួលបានការជូនដំណឹងអំពីការ "បញ្ឈប់ការរុកគួន" ពីមន្ត្រីអនុវត្តច្បាប់

ក្នុងសំណុំរឿងភាគច្រើន អ្នកដើមចោទត្រូវតែបង្ហាញថា
ក្រុមអនុវត្តច្បាប់បានចេញនូវសេចក្តីជូនដំណឹងទៅកាន់អ្នកចុងចោទ
ដើម្បីបញ្ឈប់ការរុកគួនរំខាន (ជូនកាលត្រូវបានហៅថា
ការជូនដំណឹងឲ្យបញ្ឈប់ការរុកគួន)
មុននឹងចាប់ផ្តើមសំណុំរឿងការរក្សាការពារពីការរុកគួន ។

ដើម្បីឲ្យក្រុមអនុវត្តច្បាប់ចេញលិខិតជូនដំណឹងឲ្យបញ្ឈប់ការរុកគួនចំពោះភាគីដើមចោទអ្នកត្រូវទៅកាន់ នាយកដ្ឋាននគរបាលប្រចាំមូលដ្ឋាន

ឬការិយាល័យនគរបាលប្រចាំតំបន់ ហើយរាយការណ៍អំពីការរុកគួន ដែលបានកើតឡើងចំពោះអ្នក ។ ទទួល
បានសំណៅថតចម្លងនៃការជូនដំណឹងអំពីការបញ្ឈប់ការរុកគួន ហើយដាក់ស្នើសេចក្ដីជូនដំណឹងនេះ ជាមួយនឹង *បណ្ដឹងស្នើសុំការរក្សាការពារពីការរុកគួន (PA-006) (បណ្ដឹងអំពីការរុកគួន)* របស់អ្នក ។
ក្នុងស្ថានភាពខ្លះ គឺគ្រាន់តែរាយការណ៍អំពីស្ថានការណ៍ដែលបានកើតឡើង ទៅកាន់ក្រុមអនុវត្តច្បាប់ ហើយពួកគេនឹងជួយបញ្ឈប់សកម្មភាពការរុកគួន ដែលកំពុងតែកើតឡើង ។

អ្នកមិនចាំបាច់ *ដាក់* ស្នើសំណៅសេចក្ដីជូនដំណឹងឲ្យបញ្ឈប់ការរុកគួនឡើយ បើ *បណ្ដឹងអំពីការរុកគួន* គឺសំអាងលើការរំលោភផ្លូវភេទ ការលួចមើល ឬ អំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀត ។

អ្នកក៏អាចស្នើសុំឲ្យតុលាការឲ្យបោះបង់ការជូនដំណឹងឲ្យបញ្ឈប់ការរុកគួន បានដែរ ប្រសិនបើអ្នកមានមូលហេតុល្អ ចំពោះការ
ស្នើសុំតុលាការឲ្យបោះបង់ចោលការជូនដំណឹង បែបនេះ ។

## 5. តើតុលាការមណ្ឌលណាមួយដែលអ្នកដើមចោទគប្បីប្ដឹង ?

អ្នកអាចទៅប្ដឹងនៅតុលាការមណ្ឌល ក្នុងទីកន្លែងដែលអ្នករស់នៅ ទីកន្លែងដែលអ្នកចុងចោទរស់នៅ ឬកន្លែងប្រកបមុខរបររបស់អ្នក ។ បញ្ជីឈ្មោះតុលាការមណ្ឌល មាននៅឯ ៖
www.courts.maine.gov/maine_courts/district ។

## 6. ប្រាក់កម្រៃ

គឺត្រូវបង់ថ្លៃ ចំពោះការដាក់ពាក្យ *បណ្ដឹងអំពីការរុកគួន* ប្រសិនបើ បណ្ដឹងការរុកគួនរំខាន *មិនមែនសំអាងលើមូលដ្ឋានការរំលោភបំពាន* ការដើរតាម ការរំលោភផ្លូវភេទ ការចែកចាយរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្ដែង ដោយមិនមានការយល់ព្រម ឬការជួញដូរផ្លូវភេទ ។
ក្រឡាបញ្ជីនឹងប្រាប់អ្នក ពីតម្លៃក្នុងពេលបច្ចុប្បន្ន ចំពោះការ
ដាក់បណ្ដឹងប្រភេទនេះ ។ លើសពីនេះតារាងតម្លៃការដាក់ពាក្យប្ដឹង មាននៅក្នុងបទបញ្ជារដ្ឋបាលលេខ JB-05-26 ដែលមានផ្ដល់ជូនអនឡាញ តាមអាសយដ្ឋាន ៖
www.courts.maine.gov/rules_adminorders/adminorders" ។

បើអ្នកមិនមានលទ្ធភាពអាចបង់ថ្លៃបានទេ អ្នកអាចស្នើសុំការលើកលែងពីថៅក្រម ។ ក្រឡាបញ្ជីនឹងផ្ដល់លិខិតថ្លែងសច្ចារសម្រាប់អ្នក ដើម្បីដាក់ពាក្យស្នើសុំការលើកលែងតម្លៃពីថៅក្រម ។

## 7. ជំនួយស្មារតីសម្រាប់ការបំពេញពាក្យបណ្ដឹង អំពីការរុកគួន

សូមមើលផ្នែក ក.7 ។

## 8. តើអ្នកដើមចោទអាចទទួលបានដីការក្សាការពារបណ្តោះអាសន្នពីការរុកគួន បានដែរឬទេ?

បាន ។ អ្នកដើមចោទត្រូវតែបង្ហាញឲ្យឃើញថា ខ្លួនកំពុងស្ថិតក្នុង *ភាពគ្រោះថ្នាក់មួយរំពេច*ពីការរំលោភបំពានលើរូបកាយ ឬកំពុងស្ថិតក្នុងសំពាធផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ។ ប្រសិនបើអ្នកដើមចោទគឺជាអាជីវករ អ្នកដើមចោទត្រូវតែបង្ហាញថា អាជីវកម្មរបស់ខ្លួនកំពុងតែស្ថិតក្នុងភាពគ្រោះថ្នាក់ភ្លាមៗពីការរងការខូចខាតបណ្តាលពីលទ្ធផលនៃសកម្មភាពរបស់អ្នកចុងចោទ ។

ដីការក្សាការពារបណ្តោះអាសន្នពីការរុកគួនអាចហាមឃាត់អ្នកចុងចោទមិនឲ្យប្រព្រឹត្តិចំណុចមួយចំនួន ឬចំណុចទាំងអស់ ដូចខាងក្រោម ៖

1. ការគម្រាមកំហែង ការវាយដំ ការជ្រៀតជ្រែករំខាន ការរុកគួន ការរារាំង ឬ បើមិនដូច្នេះទេ គឺការរំខានដល់សន្តិភាពនៃអ្នកដើមចោទ ឬនិយោជិករបស់អ្នកដើមចោទ
2. ការចូលមកក្នុងលំនៅដ្ឋានឬអចលនទ្រព្យរបស់អ្នកដើមចោទ
3. ការយក ការលក់ ឬការធ្វើឲ្យខូច ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬជាកម្មសិទ្ធិមួយផ្នែកដោយអ្នកដើមចោទ
4. ការដើរតាមអ្នកដើមចោទ ការមានវត្តមាននៅឯ ឬនៅជិតផ្ទះ សាលា កន្លែងប្រកបមុខរបរ ឬកន្លែងធ្វើការរបស់អ្នក ដើមចោទម្តងហើយម្តងទៀត ដោយមិនមានមូលហេតុសមរម្យ
5. ការមានទំនាក់ទំនងផ្ទាល់ឬដោយប្រយោល ជាមួយអ្នកដើមចោទ ឬ
6. ការបំផ្លាញ ការផ្ទេរ ឬធ្វើឲ្យខូចលិខិតឆ្លងដែន ឬឯកសារអន្តោប្រវេសន៍ដទៃទៀត ដែលនៅក្នុងដៃអ្នកចុងចោទ ។

សូមមើលផ្នែក ក.8 សម្រាប់ព័ត៌មានបន្ថែមលើដំណើរការសម្រាប់ការទទួលបានដីការក្សាការពារបណ្តោះអាសន្ន ពីតុលាការ ។

## 9. តើសវនាការសម្រេចចំពោះសំណុំរឿងការរក្សាការពារពីការរុកគួនត្រូវធ្វើឡើងនៅពេលណា?

សវនាការសម្រេចក្នុងសំណុំរឿងការរក្សាការពារពីការរុកគួននឹងត្រូវគ្រោងពេលធ្វើឲ្យបានលឿន ទៅតាម កាលបរិច្ឆេទទំនេរ តែវាខុសពីសំណុំរឿងការរក្សាការពារពីការរំលោភបំពានគឺមិនបាច់ត្រូវតែធ្វើឡើងក្នុងរវាង 21 ថ្ងៃឡើយ ។

## 10. សេវាកម្មចំពោះអ្នកចុងចោទ

ទម្រង់ *ដីកាកោះហៅ* បណ្តឹង *អំពីការរុកគួន* និងទម្រង់បន្ថែមដែលត្រូវបានដាក់ស្នើដល់តុលាការ គឺត្រូវតែផ្ញើមួយច្បាប់ទៅដល់ដៃអ្នកចុងចោទមុនពេលត្រូវធ្វើសវនាការ ។

បើតុលាការផ្តល់ឲ្យអ្នកនូវដីការក្សាការពារបណ្តោះអាសន្ន ជាទូទៅតុលាការនឹងរៀបចំសេវាកម្មដល់ចុងចោទបានដឹង ។ ជាលក្ខណៈម្តងម្កាល តុលាការអាចស្នើសុំអ្នកដើមចោទដែលយល់ព្រមធ្វើបែបនេះឲ្យយកសំណៅក្រដាសស្នាមតុលាការ ទៅប្រគល់ឲ្យនាយកដ្ឋាននគរបាល ឬការិយាល័យនគរបាលតំបន់ ដើម្បីពន្លឿនសេវាកម្មចំពោះអ្នកចុងចោទ ។ នេះមិនមែនជាកិច្ចការ ដែលអ្នកត្រូវធ្វើឡើយ ។

មិនមានថ្លៃក្នុងការផ្តល់សេវាកម្មឡើយ បើ ៖

- *បណ្តឹងអំពីការរុកគួន*ពាក់ព័ន្ធនឹងហិង្សាក្នុងគ្រួសារ ឬហិង្សាស្នេហា ការរំលោភផ្លូវភេទ ការឈ្លបមើល ការចែកចាយរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែង ឬការជួញដូរផ្លូវភេទ ឬ
- តុលាការ ផ្តល់ដីការក្សាការពារបណ្តោះអាសន្ន ពីការរុកគួន ដោយមិនគិតថា វាជាមួយហេតុអ្វីទេនោះ ។

ដូចគ្នានឹងដីការក្សាការពារពីការរំលោភបំពានដែរ សវនាការសម្រេចនឹងធ្វើទេ ប្រសិនបើ អ្នកចុងចោទ នៅមិនទាន់បានទទួលការជូនដំណឹងជាផ្លូវការអំពីសំណុំរឿង (បានទទួលសេវាកម្ម) ។

សូមមើលព័ត៌មានបន្ថែមអំពីសេវាកម្មក្នុងផ្នែក ក.10 ។

## 11. សិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកចុងចោទក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន

អ្នកចុងចោទក្នុងការរក្សាការពារចំពោះសំណុំរឿងការរុកគួនមានសិទ្ធិគឺមានសិទ្ធិ និងការទទួលខុសត្រូវដូចគ្នាទៅនឹងអ្នកចុងចោទនៅក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន ។ សូមមើលផ្នែក ក.12 ។

## 12. ការគ្រោងពេលធ្វើសវនាការសម្រេចក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន

ក្រឡាបញ្ជីនឹងគ្រោងពេលធ្វើពេលសវនាការសម្រេចអំពីសំណុំរឿងការរក្សាការពារពីការរុកគួន បន្ទាប់ពីចៅក្រមបានចុះហត្ថលេខាលើដីការក្សាការពារបណ្តោះអាសន្ន ។

បើតុលាការបានសម្រេចមិនចេញដីការក្សាការពារបណ្តោះអាសន្ន សវនាការសម្រេចនៅតែអាចត្រូវបានគ្រោងពេលដដែល ។

អ្នកចុងចោទត្រូវទទួលបានការជូនដំណឹង (បានទទួលសេវាកម្ម) មុនកាលបរិច្ឆេទសវនាការសម្រេចចូលមកដល់ ។ សវនាការសម្រេចនឹងត្រូវគ្រោងពេលធ្វើ ក្នុងកាលបរិច្ឆេទដែលឆាប់បំផុត ។ សូមមើលផ្នែក ក.14 និង ក.16 សម្រាប់ព័ត៌មានពាក់ព័ន្ធនឹងសវនាការសម្រេច ។

## 13. ដីកាដោយមានការយល់ព្រម (ដោយគ្មានសវនាការ)

តុលាការចេញដីកា ដោយមានការយល់ព្រមពីគូភាគីក្នុងវិវាទ ក្នុងសំណុំរឿងការរក្សាការពារពីការរុកគួន ក្នុងរបៀបដូចគ្នា នឹងការចេញដីការក្សាការពារចំពោះសំណុំរឿងការវាយរំលោភបំពានដែរ។ សូមមើលផ្នែក ក.15 ។

តុលាការក៏អាចពិភាក្សាជាមួយគូភាគីវិវាទ ដើម្បីរុករកដំណោះស្រាយផ្សេងជាជម្រើស ឬក៏រៀបចំធ្វើការសម្រុះសម្រួលដែលច្បាប់តម្រូវឲ្យធ្វើ ដើម្បីជួយគូភាគីក្នុងវិវាទ ដោះស្រាយសំណុំរឿង ដោយមិនបាច់មានសវនាការពេញលេញ ។

## 14. តើនឹងមានអ្វីកើតឡើងនៅក្នុងសវនាការសម្រេច?

ប្រសិនបើសវនាការសម្រេចត្រូវបានធ្វើឡើង ដំណើរការសវនាការគឺមានភាពដូចគ្នា សវនាការសម្រេចចំពោះសំណុំរឿងការរក្សាការពារពីការរំលោភបំពាន ដែរ ។ សូមមើលផ្នែក ក.16 ។

## 15. តើដំណោះស្រាយអ្វីខ្លះ អាចត្រូវបានដាក់បញ្ចូលក្នុងដីការក្សាការពារសម្រេចពីការរុកគួន?

ខ្លឹមសារក្នុងដីការក្សាការពារសម្រេចពីការរុកគួនអាចហាមឃាត់អ្នកចុងចោទមិនឲ្យប្រព្រឹត្តលើចំណុចមួយចំនួន ឬគ្រប់ចំណុចទាំងអស់ ដូចតទៅ ៖

1. ការរុកគួន ការគម្រាមកំហែង ការវាយដំ ការជ្រៀតជ្រែក ការវាយប្រហារ ឬបើមិនដូច្នេះទេ គឺជាការវាយរំលោភបំពានអ្នកដើមចោទ ឬវាយរំលោភបំពាននិយោជិក របស់អ្នកដើមចោទ

2. ចូលមកក្នុងអចលនទ្រព្យ ឬលំនៅដ្ឋានរបស់អ្នកដើមចោទ

3. ការជ្រៀតជ្រែក ឬការបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកដើមចោទ

4. បានបណ្ដាលដោយគ្មានហេតុផល ម្ដងហើយម្ដងទៀត ការលបដើរតាមអ្នកដើមចោទ មានវត្តមាននៅក្នុង ឬនៅក្បែរផ្ទះ សាលា កន្លែងធ្វើអាជីវកម្ម ឬកន្លែងធ្វើការការរបស់អ្នក ដើមចោទ ម្ដងហើយម្ដងទៀត និងដោយមិនមានមូលហេតុសមរម្យ

5. មានការទាក់ទងដោយផ្ទាល់ ឬ ប្រយោលណាមួយជាមួយអ្នកដើមចោទ និង

6. ការបំផ្លាញ ការផ្ទេរ ឬការកែប្រែលិខិតឆ្លងដែន ឬឯកសារអន្តោប្រវេសន៍ របស់អ្នកដើមចោទ ដែលកំពុងស្ថិតក្នុងដៃរបស់អ្នកចុងចោទ ។

ដីកាសម្រេចក៏អាចតម្រូវឲ្យអ្នកចុងចោទបង់ប្រាក់ទៅឲ្យអ្នកដើមចោទចំពោះការរងការបាត់បង់/ខូចខាត
ដែលបានកើតឡើងដោយផ្ទាល់ពីសកម្មភាពរុកគួនរបស់ខ្លួន ។ ការបាត់បង់គឺបានត្រូវបានកំណត់ ចំពោះរបស់ដូចខាងក្រោម ៖

1. ការបាត់បង់ប្រាក់ចំណូល ឬប្រាក់ឧបត្ថម្ភ
2. ការចំណាយសមហេតុផល ដែលបានធ្វើឡើង សម្រាប់ការរក្សាការពារសុវត្ថិភាព
3. ការចំណាយសមហេតុផល ដែលធ្វើឡើងចំពោះរបួសស្នាមលើរាងកាយ ឬការខូចខាតទ្រព្យសម្បត្តិ
4. ការចំណាយសមហេតុផលទៅលើការរើលំនៅដ្ឋាន និង
5. ការខូចខាតពាក់ព័ន្ធនឹងការប្រគល់ត្រឡប់ ឬការធ្វើឲ្យដូចដើមវិញនូវលិខិតឆ្លងដែនប័ណ្ណឯកសារអន្តោប្រវេសន៍ឯទៀត និងប័ណ្ណបំណុលណាមួយ កើតឡើងពីទំនាក់ទំនងនៃការជួញដូរផ្លូវភេទរបស់អ្នកដើមចោទ ។

ចៅក្រមអាចបង្គាប់អ្នកចុងចោទឲ្យបង់ថ្លៃតុលាការ និង/ឬបង់ប្រាក់ថ្លៃមេធាវី ។

ចំពោះដីកាផ្សេងទៀត ចៅក្រមអាចបង្គាប់ឲ្យអ្នកដើមចោទបង់ថ្លៃតុលាការ និង/ឬប្រាក់កម្រៃមេធាវី ។ ស្ថានភាពនេះ អាចកើតឡើងតែក្នុងករណីដែល *អ្នកដើមចោទបានចាញ់ក្តី ហើយតុលាការសម្រេចថាបណ្តឹងការបង្កការរុកគួនរបស់អ្នកមិនសមហេតុផលប៉ុណ្ណោះ* ។

ដីកា អាចបញ្ជាក់អំពីដំណោះស្រាយណាមួយ ដែលមានភាពចាំបាច់ និងសមរម្យ ។

### 16. តើដីការក្សាការពារសម្រេចពីការរំលោភបំពានមានប្រសិទ្ធិភាពយូរប៉ុណ្ណា?

រហូតដល់មួយ (1) ឆ្នាំ ។

### 17. តើត្រូវធ្វើដូចម្តេច បើអ្នកចុងចោទប្រព្រឹត្តបំពានដីការក្សាការពាររបស់តុលាការ ពីការរុកគួន?

ប្រសិនបើអ្នកចុងចោទបំពានដីការក្សាការពារពីការរុកគួន អ្នកចុងចោទអាចមានកំហុសលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម D ហើយអាចរងការចាប់ខ្លួន ពិន័យ ឬក៏ជាការប្រមាថតុលាការ (ប្រសិនបើអ្នកចុងចោទខកខានបង់ប្រាក់ថ្លៃខូចខាត ដែលតុលាការបង្គាប់ឲ្យធ្វើ) ។ សូមមើលផ្នែក ក.19 សម្រាប់ព័ត៌មានបន្ថែមអំពីអ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកចុងចោទ បំពានលើដីការក្សាការពារពីការរុកគួន ។

### 18. ការកែសម្រួលនិងការពន្យារសុពលភាពនៃដីការក្សាការពារពីការរុកគួន

ចំពោះដំណើរការទូទៅដែលប្រើដើម្បីការកែសម្រួល ឬការពន្យារសុពលភាពនៃដីការក្សាការពារពីការរុកគួន គឺដូចគ្នាចំពោះដំណើរការក្នុងការស្នើសុំពន្យារសុពលភាពការរក្សាការពារពីការរំលោភបំពានដែរ ។ ទាំងអ្នក

ដើមចោទ និងអ្នកចុងចោទអាចស្នើសុំឲ្យតុលាការកែសម្រួល ឬពន្យារសុពលភាពលើដីការក្សាការពារ ពីការរុកគួន ។ សូមមើលផ្នែក ក.20 និង ក.21 ។

## 19. ដីការក្សាការពារពីការរុកគួនដែលបានចេញដោយរដ្ឋផ្សេងទៀត

ដីការក្សាការពារពីការរុកគួន ដែលចេញមកដោយរដ្ឋមួយទៀត គឺមានតម្លៃដូចគ្នានឹងដីការក្សាការពារ ដែលចេញដោយតុលាការ រដ្ឋមេន ដែរ ។ សូមមើលផ្នែក ក.22 នៃសៀវភៅគោលការណ៍ណែនាំ សម្រាប់សិទ្ធិ និងការទទួលខុសត្រូវ ចំពោះ អ្នកដើមចោទ និងអ្នកចុងចោទ ។

## និយមន័យនៃពាក្យគន្លឹះ

**ការរំលោភបំពាន ៖** ការប៉ុនប៉ងបង្ក ឬការបង្កឲ្យមានរបួសលើរាងកាយ ឬការវាយប៉ះពាល់ រួមទាំងការរំលោភផ្លូវភេទ ការប៉ុនប៉ងធ្វើឲ្យ ឬធ្វើឲ្យនរណាម្នាក់ ឲ្យស្ថិតក្នុងភាពភ័យខ្លាចពីការមានរបួសលើរូបកាយ តាមរយៈអាកប្បកិរិយាគម្រាមកំហែង ការរុកគួន ឬអាកប្បកិរិយាទារុណកម្ម ការបង្ខំជនម្នាក់ដោយកម្លាំង គម្រាមប្រើកម្លាំង ឬការបំភ័យឲ្យធ្វើមួយ ដែលបុគ្គលនោះ មានសិទ្ធិ ឬឯកសិទ្ធិទទួលបានពីការធ្វើអ្វីមួយ ការដាក់កម្រិតដោយចេតនាធំធេង នូវសកម្មភាពរបស់ជនម្នាក់ទៀត ដោយគ្មានយល់ព្រមពីជននោះ ការទាក់ទងជននោះដោយពាក្យគម្រាមកំហែងឲ្យធ្វើអ្វីមួយ ឬធ្វើឲ្យប្រព្រឹត្តិបទឧក្រិដ្ឋនៃអំពើហិង្សាគ្រោះថ្នាក់ចំពោះជីវិតរបស់មនុស្សម្តងហើយម្តងទៀត និង ដោយគ្មានបុព្វហេតុសមហេតុផល ការដើរតាមអ្នកដើមចោទ ឬនៅក្នុងទីកន្លែងរបស់អ្នកដើមចោទ ដូចជាផ្ទះ សាលារៀន ពាណិជ្ជកម្ម ឬ ការងាររបស់អ្នកដើមចោទ ដោយបំណងរុកគួនដាក់ទារុណកម្ម ឬ គម្រាមកំហែង ការចែករំលែករូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែងរបស់អ្នកដើមចោទ ឬ ជនម្នាក់ទៀតដោយគ្មានការយល់ព្រម ឬ ការចូលរួមក្នុងការជួញដូរផ្លូវភេទ ឬ ការជួញដូរផ្លូវភេទសកម្ម ។

**នីតិជន ៖** បុគ្គលដែលមានអាយុដប់ប្រាំបី (18) ឆ្នាំ ឬ ចាស់ជាង ឬ អនីតិជនរួចផុតពីការគ្រប់គ្រងរបស់អាណាព្យាបាល ។

**លិខិតថ្លែងសច្ចារ ៖** សេចក្តីថ្លែងការជាលាយលក្ខណ៍អក្សរ ដែលបានធ្វើឡើងដោយស្ម័គ្រចិត្ត និងចុះហត្ថលេខាក្រោមពាក្យសម្បថ ។

**ការជួញដូរផ្លូវភេទសកម្ម ៖** ការបង្ខំបុគ្គលម្នាក់ឲ្យចូលក្នុងពាក់ព័ន្ធ ឬស្ថិតក្នុងពេស្យាចារតាមរយៈការបង្ខំ ការគម្រាមកំហែងប្រើកម្លាំង ការបង្ខិតបង្ខំ ឬការគៃបន្លំ ការលើកកំពស់ពេស្យាចារនៃបុគ្គលម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំ ឬការជម្រុញឲ្យមនុស្សពិការភាពផ្លូវចិត្តធ្វើពេស្យាចារ ដូចដែលបានផ្តល់និយមនិយម នៅក្នុងចំណងជើងច្បាប់ 17:A នៃនីតិក្រមកែសម្រួលរបស់រដ្ឋមេន ផ្នែកទី 852 ។

**ទទ្បីករណ៍ ៖** សេចក្តីថ្លែងការ ឬការអះអាង ដែលសរសេរក្នុងពាក្យបណ្តឹង និងឯកសារផ្សេងទៀតរបស់តុលាការ ដែលនៅមិនទាន់មានភ័ស្តុតាងបញ្ជាក់នៅឡើយ ។

**សំណៅថតចម្លងពិត៖** ជាសំណៅនៃដីកា ឬសំណៅឯកសារផ្សេងទៀតរបស់តុលាការ ដែលមាន ៖ 1) ត្រា ឬហត្ថលេខារបស់ក្រឡាបញ្ជីតុលាការយកជាកសិណថា ឯកសារនេះគឺជាសំណៅថតចម្លងពិតប្រាកដ 2) ការយកជាកសិណរបស់ចៅក្រម ដែលបញ្ជាក់ថា ក្រឡាបញ្ជីនេះ គឺជាក្រឡាបញ្ជីនៃតុលាការខាងលើ ហើយក៏ជាមនុស្សត្រឹមត្រូវសម្រាប់ធ្វើ និងបញ្ជាក់ឯកសារខាងលើ និង 3) ការយកជាកសិណបន្ថែមរបស់ក្រឡាបញ្ជីដែលថា ចៅក្រមដែលចុះហត្ថលេខាលើឯកសារនេះ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានទទួលការអនុញ្ញាតឲ្យចុះហត្ថលេខា ហើយថាជាបុគ្គលត្រឹមត្រូវ ដើម្បីធ្វើ និងបញ្ជាក់ជូនចំពោះឯកសារនេះ ។ ក្នុងរដ្ឋមេន សកម្មភាពនេះជួនកាលគឺសំដៅលើពាក្យថា “ការបង្ហាញ” ។

**បណ្ដឹង** ៖ ជាពាក្យដែលប្រើសម្រាប់ហៅឯកសារដំបូងដែលត្រូវបានដាក់ប្ដឹងមកតុលាការ ដើម្បីចាប់ផ្ដើមសំណុំរឿង ។ ទម្រង់ PA-001 គឺត្រូវបានប្រើ សម្រាប់សំណុំរឿងលើការរក្សាការពារពីរំលោភបំពាន និងទម្រង់ PA-006 គឺត្រូវប្រើសម្រាប់សំណុំរឿងការរក្សាការពារពីការរុកគួន ។

**ការបន្ត** ៖ ការផ្អាកសវនាការដោយមានសំណើជាលាយលក្ខណ៍អក្សរ របស់ភាគីមួយ ឬទាំងពីរភាគី ។ មានតែចៅក្រមទេដែលអាចផ្ដល់ការបន្តនេះបាន ។

**អាវុធគ្រោះថ្នាក់**៖ កាំភ្លើង ឬឧបករណ៍ដទៃ គ្រឿង សម្ភារៈ ឬសារធាតុ មិនថាមាន ឬមិនមានចលនា ដែលគេប្រើជាអាវុធ ហើយមានសមត្ថភាពអាចផ្ដាច់ជីវិត ឬបង្ករបួសស្នាមធ្ងន់ធ្ងរលើរាងកាយ ។

**ដៃគូស្នេហា**៖ បុគ្គលដែលបច្ចុប្បន្ន ឬពីមុន មានស្នេហានឹងគ្នា មិនថាបុគ្គលនោះ កំពុង ឬធ្លាប់ជាដៃគូរួមភេទជាមួយគ្នាឡើយ ។

**អ្នកចុងចោទ** ៖ បុគ្គលដែលប្ដឹងនៅក្នុងសំណុំរឿង ។

**នីតិជនស្ថិតក្រោមបន្ទុក**៖ ជានីតិជនដែលមានពិការភាពខាងរូបកាយ ឬខាងផ្លូវចិត្ត ធ្វើឲ្យបាត់បង់យ៉ាងខ្លាំង នូវសមត្ថភាពជានីតិជន ដើម្បីមើលខុសត្រូវអំពីតម្រូវការប្រចាំថ្ងៃរបស់ខ្លួន ឲ្យបានសមរម្យ ។

**ការប៉ះពាល់ផ្ទាល់** ៖ គ្រប់ពេលដែលអ្នកចុងចោទ ស្ថិតក្នុងរូបនិយាមក្បែរអ្នកដើមចោទ ឬការប៉ុនប៉ងណាមួយ ដើម្បីទាក់ទង អ្នកដើមចោទ តាមរយៈវិធីផ្សេង រួមទាំងទូរស័ព្ទ លិខិត អ៊ីមែល សារជាអក្សរ ឬ សារលិខិត ពីអ្នកចុងចោទដាក់តាំងលើគណនីបណ្ដាញប្រព័ន្ធសង្គមរបស់អ្នកដើមចោទ ។

**រំលាយ** ៖ ដើម្បីបញ្ចប់ដីការក្សាការពារបណ្ដោះអាសន្នឬដីការក្សាការពារសម្រេច ។ ជួនកាល តុលាការប្រើពាក្យ “បញ្ចប់” ដែលពាក្យនេះ គឺមានន័យដូចគ្នា ។

**អនីតិជនរួចផុតពីការគ្រប់គ្រងរបស់អាណាព្យាបាល** ៖
ជាមនុស្សមានអាយុក្រោម ដប់ប្រាំបី (18) ឆ្នាំដែលត្រូវបានដោះលែងឲ្យរួចផុតពីការគ្រប់គ្រងរបស់អាណាព្យាបាល ដោយដីកាតុលាការ ។

**ទុក្ខលំបាកខាងផ្លូវចិត្ត** ៖ ការរងទុក្ខលំបាកផ្លូវចិត្ត ឬអារម្មណ៍ ដែលបង្ហាញឡើងដោយការភ័យខ្លាច ក្ដីអន្ទះសារ ការឈឺចាប់ ឬការថប់បារម្ភ ។

**សមាជិកគ្រួសារសាច់ឆ្ងាយ** ៖ សមាជិកណាម្នាក់នៃគ្រួសារ ដែលជាប់ទាក់ទងជាឈាម អាពាហ៍ពិពាហ៍ ឬ ការយកមកចិញ្ចឹម ។

**សមាជិកគ្រួសារ ឬក្រុមគ្រួសារ** ៖ ប្ដីឬប្រពន្ធ ឬ ប្ដីឬប្រពន្ធមុន ដៃគូក្នុងផ្ទះ ឬអតីតដៃគូក្នុងផ្ទះ បុគ្គលដែល ធ្លាប់ដែល រស់នៅជាមួយគ្នា ឪពុកម្ដាយនៃកូនតែមួយនីតិជនជាមេក្រុមគ្រួសារ ជាប់ទាក់ទងសាច់ឈាម ឬ អាពាហ៍ពិពាហ៍ កុមារអនីតិជន នៃសមាជិកក្រុមគ្រួសារ នៅពេលដែលអ្នកចុងចោទ គឺជានីតិជនសមាជិកក្រុមគ្រួសារ ឬ ដៃគូបច្ចុប្បន្ន ឬ អតីតដើរលេងជាមួយគ្នា ។

**ដាក់ពាក្យបណ្ដឹង** ៖ ដាក់ពាក្យបណ្ដឹង គឺបំពេញ និងដាក់ស្នើទម្រង់ ឬឯកសារចូល (ការដាក់ពាក្យបណ្ដឹង) ដើម្បីចាប់ផ្ដើមសំណុំរឿង ឬ ស្នើសុំតុលាការដើម្បីធ្វើអ្វីមួយចំពោះសំណុំរឿង ។

**ដីកាសម្រេច** ៖ ក្នុងករណីនៃសំណុំរឿងដែលស្ថិតក្រោមច្បាប់រក្សាការពារ គឺជាដីកា ដែលចៅក្រមផ្ដល់ឲ្យនៅសវនាការសម្រេច ។ សូមមើលផងដែរនូវដីកា និងដីការក្សាការពារបណ្ដោះអាសន្ន របស់តុលាការ ។

**ការកេងប្រវ័ញ្ចហិរញ្ញវត្ថុ**៖ ការឆបោក ការបំភ័យ ការប្រើឥទ្ធិពលជ្រុល ការប្រើមធ្យោបាយផ្សេងទៀតដោយការបង្ខំ ឬមធ្យោបាយខុសច្បាប់ ដើម្បីបានគ្រប់គ្រង លើទ្រព្យសម្បត្តិរបស់នីតិជនក្នុងបន្ទុក ដើម្បីទទួលបានផលចំណេញ ឬអត្ថប្រយោជន៍ផ្សេងទៀត ។

**ការស្វែងរកការពិត** ៖ សេចក្ដីសម្រេចរបស់ចៅក្រម អំពីសំណួរឬរឿងរ៉ាវសំអាងទៅលើការពិត ។

**គ្មានខ្លឹមសារ** ៖ ការរកឃើញដោយចៅក្រម ដែលថា ការចោទប្រកាន់ក្នុងបណ្ដឹង ឬនៅក្នុងសំណុំឯកសារឯទៀត គឺខ្វះមូលដ្ឋានការពិត ហើយមានចេតនាដើម្បីបង្កការរុកគួន បង្កឧបសគ្គ ឬពន្យឺតដំណើរការតុលាការ ។

**អ្នកអាណាព្យាបាល** ៖ បុគ្គលដែលមានសិទ្ធិ និងភារកិច្ចផ្លូវច្បាប់ ដើម្បីជួយទំនុកបម្រុងផលប្រយោជន៍នៃអ្នកដទៃ ។ ឪពុក ឬ ម្ដាយ ជាធម្មតា គឺជាអាណាព្យាបាលនៃកូនរបស់ខ្លួន ។ អាណាព្យាបាល ក៏អាចជាបុគ្គល ឬជាទីភ្នាក់ងាររដ្ឋាភិបាល ដែលបានទទួលការតែងតាំងដោយស្របច្បាប់ តាងនាមឲ្យកុមារ ឬនីតិជនអសមត្ថភាព ឬនីតិជនរស់នៅក្រោមបន្ទុក ។

**ការរុកគួន** ៖ នៅក្រោមច្បាប់រក្សាការពារ អំពើបី (3) ឬច្រើន អំពីការបំភិតបំភ័យ ការប្រឈមមុខតតាំង ការប្រើកម្លាំងកាយពិត ឬការគម្រាមកំហែងប្រើកម្លាំងកាយ ដោយអ្នកចុងចោទ បានធ្វើឡើងដោយបំណងនៃការបង្កើតឲ្យមានការភ័យខ្លាច ការបំភ័យ ឬបង្កការខូចខាតចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយដែលការពិត គឺបង្កឲ្យមានការភ័យខ្លាច ឬការខូចខាតទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬ ជាអំពើ ឬ ដំណើរការនៃអាកប្បកិរិយាដែលបង្កើតជាការប្រព្រឹត្តអំពើព្រហ្មទណ្ឌធ្ងន់ធ្ងរ ឬ ការបំពាន ឬ ការរំខានចំពោះសិទ្ធិរដ្ឋ ធម្មនុញ ឬសិទ្ធិរដ្ឋប្បវេណីរបស់អ្នកដើមចោទ ។

**សវនាការ** ៖ នីតិក្រមតុលាការចំពោះមុខចៅក្រម ដែលមានលក្ខណៈស្រដៀងគ្នានឹងការកាត់ក្ដី ។

**នីតិជនអសមត្ថភាព**៖ នីតិជនដែលពិការដោយមូលហេតុនៃជំងឺផ្លូវចិត្ត ភាពយឺតយ៉ាវនៃការលូតលាស់ផ្នែកប្រាជ្ញាស្មារតី ជំងឺរូបកាយ ឬ ពិការភាពក្នុងកម្រិតមួយដែលធ្វើឲ្យរូបគេ ខ្វះខាតសមត្ថភាពការយល់ដឹង ឬ ខ្វះខាតសមត្ថភាព ដើម្បីធ្វើ ឬ ទំនាក់ទំនងការសម្រេចចិត្តចំពោះខ្លួនដោយមានការទទួលខុសត្រូវ ឬក្នុងកម្រិតមួយដែល រូបគេ មិនអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួន ដោយមានប្រសិទ្ធភាព ។

**ការទាក់ទងប្រយោល** ៖ ការប្រឹងប្រែងណាមួយដោយអ្នកចុងចោទ ដើម្បីទាក់ទងអ្នកដើមចោទ តាមរយៈអ្នកផ្សេងទៀត រួមទាំងការឲ្យអ្នកផ្សេងទៀតឲ្យលិខិត ឬ រូបភាព ឬ បញ្ជូនអ៊ីមែល ឬសារដំណឹងប្រព័ន្ធព័ត៌មានសង្គម ទៅអ្នកដើមចោទ ។

**បុគ្គល** ៖ បុគ្គលធម្មជាតិ មនុស្សលោកដែលមានភាពខុសគ្នាពីអាជីវកម្ម ឬអង្គភាព ។

**កុមារអនីតិជន** ៖ បុគ្គលមានអាយុក្រោមដប់ប្រាំបី (18) ឆ្នាំ ។

**កែប្រែ** ៖ ដើម្បីធ្វើការផ្លាស់ប្តូរទៅលើលក្ខខណ្ឌនៃដីកាក្នុងការឆ្លើយតបទៅនឹងសំណើនៃភាគីក្នុងវិវាទ ប្រសិនបើអនុញ្ញាតឲ្យធ្វើ ។

**ញត្តិ** ៖ ពាក្យសុំជាលាយលក្ខណ៍អក្សរ របស់ភាគីណាមួយផ្ញើទៅកាន់តុលាការ ។

**ដីកា** ៖ សេចក្តីណែនាំរបស់ចៅក្រមចំពោះភាគីមួយ ឬ ទាំងពីរឲ្យធ្វើ ឬ មិនឲ្យធ្វើអ្វីមួយ ។ ក្នុងសំណុំរឿងនៅក្រោមច្បាប់រក្សាការពារ ចៅក្រមអាចចេញដីការក្សាការពារបណ្តោះអាសន្ន ដីការក្សាការពារសម្រេច (បន្ទាប់ពីសវនាការចុងក្រោយ) ឬ ដីកាដោយមានការយល់ព្រម (បានយល់ព្រមដោយអ្នកដើមចោទ និងអ្នកចុងចោទ) ។

**ភាពជាឪពុកឬម្តាយ** ៖ ទំនាក់ទំនងពេញច្បាប់រវាងកុមារនិង ឪពុកឬម្តាយឋានៈពេញច្បាប់ នៃការធ្វើជាឪពុកឬម្តាយ ។

**ភាគី** ៖ អ្នកដើមចោទ និងអ្នកចុងចោទក្នុងសំណុំរឿងតុលាការ ។ ចំពោះពាក្យជាឯកវចនៈវិញគឺ ភាគី គឺសំដៅលើអ្នកដើមចោទ ឬ អ្នកចុងចោទ ។

**អ្នកដើមចោទ** ៖ បុគ្គលដែលដាក់ពាក្យបណ្តឹងអំពីសំណុំរឿង ។

**រូបភាពឯកជន រូបឯកជនអាសអាភាសជាក់ស្តែង** ៖ ក្នុងសំណុំរឿងក្រោមច្បាប់រក្សាការពារ រូបថត វីដេអូ កាសែត ខ្សែភាពយន្ត ឬ ការថតជាឌីជីថលនៃអ្នកដើមចោទ ឬ ជនណាម្នាក់ទៀត ក្នុងភាពអាក្រាត ឬ ប្រព្រឹត្តិការរួមភេទ ឬ បង្កើតការប្រព្រឹត្តិនៃការរួមភេទ ដែលអ្នកចុងចោទបានចែកចាយដោយគ្មានការយល់ព្រមរបស់អ្នកដើមចោទ ដោយបំណងដើម្បីរុកគួន ធ្វើឲ្យឈឺចាប់ ឬ គម្រាមកំហែង ។

**ដំណោះស្រាយ** ៖ ការរក្សាការពារជាក់លាក់ដែលបានស្នើសុំដោយភាគីមួយ ឬដីការបស់ចៅក្រម ។

**អំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ** ៖ ក្នុងសំណុំរឿងក្រោមច្បាប់រក្សាការពារ ពីការរុកគួនការបំពានដែលបានធ្វើឡើងដោយអ្នកចុងចោទ លើ ផ្នែកណាមួយខាងក្រោមនៃចំណងជើង 17-A នៃច្បាប់កែសម្រួលរបស់រដ្ឋមេន ៖ 201(ឃាតកម្ម); 202 (ឃាតកម្មឧក្រិដ្ឋកម្មធ្ងន់ធ្ងរ); 203 (ការសម្លាប់មនុស្ស); 204 (ជួយនិងការធ្វើអត្តឃាត); 207 (ការវាយតប់); 208 (ការវាយតប់ធ្ងន់ធ្ងរ); 209 (ឧក្រិដ្ឋកម្មដោយការការគម្រាមកំហែង); 210 (ភេរវកម្ម); 210-A

(ការឈ្លបតាម); 211 (ការធ្វើឲ្យអ្នកដទៃគ្រោះថ្នាក់ដោយភាពមិនប្រយ័ត្នប្រយែង); 253 (ការរំលោភផ្លូវភេទធ្ងន់ធ្ងរ); 301 (ការចាប់ជំរិត); 302 (ឧក្រិដ្ឋកម្មពីការឃុំអ្នកដទៃ); 303 (ឧក្រិដ្ឋកម្មពីការឃុំខ្លួនកូនពីសំណាក់ឪពុកឬម្តាយ); 506-A (ការរុកគួន); 511 (ការបំពានភាពឯកជន); 511-A (ការចែកចាយរូបភាពឯកជន រូបភាពអាសអាភាសជាក់ស្តែង); 556 (ស្មុនការីវិនី); 802 (ការបង្កអគ្គីភ័យ); 805 (អំពើព្រហ្មទណ្ឌរៀចរេធ្ងន់ធ្ងរ); 806 (អំពើព្រហ្មទណ្ឌរៀចរេ); 852 (ការជួញដូរផ្លូវភេទសកម្ម); និង 853 (ការជួញដូរផ្លូវភេទ) ។

**សេវាកម្ម** ៖ ដំណើរការនៃការផ្តល់ដល់ភាគីក្នុងវិវាទនូវការជូនដំណឹងផ្លូវការអំពីសំណុំរឿង ឬ សំណើដោយភាគីឯទៀត ដើម្បីឲ្យបុគ្គលដែលទទួលការជូនដំណឹង និងក្រដាសស្នាមពេញច្បាប់អាចឆ្លើយតប ។

**ការជួញដូរផ្លូវភេទ** ៖ សកម្មភាព ឬអាកប្បកិរិយារបស់អ្នកចុងចោទដើម្បីជម្រុញនីតិជនឲ្យចូលក្នុង ចូលរួម ឬ បន្តស្ថិតនៅក្នុងពេស្យាចារ ដូចដែលបាន ផ្តល់ជានិយមន័យក្នុងចំណងជើងច្បាប់ 17-A នៃនីតិច្បាប់រដ្ឋមេនដែលបានកែសម្រួល ត្រង់ផ្នែកទី 853 ។

**ការរំលោភផ្លូវភេទ** ៖ ក្នុងសំណុំរឿងក្រោមច្បាប់រក្សាការពារការរំលោភផ្លូវភេទក្នុងចំណងជើងច្បាប់ 17-A នៃនីតិច្បាប់រដ្ឋមេនដែលបានកែសម្រួល ត្រង់ផ្នែកទី 251-261 រួមមានការវាយដំរំលោភផ្លូវភេទ ឬ ការប៉ះពាល់ផ្លូវភេទដោយខុសច្បាប់ ។

**ការឈ្លបតាម** ៖ អំពើពីរ (2) ឬច្រើន ដែលធ្វើឡើងដោយអ្នកចុងចោទទាក់ទងនឹងការដើរតាម ការឃ្លាំមើល ការគម្រាមកំហែង ការរុកគួន ការជ្រៀតជ្រែករឿងទ្រព្យសម្បត្តិ ឬ ការទាក់ទងជាមួយ ឬ អំពីជនណាម្នាក់ជាមួយគោលបំណងនៃការធ្វើឲ្យអ្នកដើមចោទទទួលរងភាពមិនសុខស្រួល ឬទុក្ខ លំបាកផ្លូវចិត្ត ការភ័យខ្លាចចំពោះគ្រោះថ្នាក់ដល់រូបកាយ (អ្នកដើមចោទ ឬ សាច់ញាតិជិតស្និទ្ធ) ភ័យខ្លាចចំពោះការខូចខាត ឬភ័យខ្លាចពីការបំផ្លាញ ទ្រព្យសម្បត្តិ ឬខ្លាចរងគ្រោះថ្នាក់ គ្រោះថ្នាក់ ឬការស្លាប់នៃសត្វដែលជាកម្មសិទ្ធិ ឬសត្វដែលបានរក្សាទុកដោយអ្នកដើមចោទ ។

**លិខិតថ្លែងសច្ចារ** ៖ ដីការបស់ចៅក្រមក្នុងការបង្គាប់ឲ្យបុគ្គលម្នាក់បង្ហាញខ្លួននៅតុលាការ តាមកាលបរិច្ឆេទ និងពេលវេលា កំណត់ ។

**ការកោះហៅ** ៖ ដីការបស់ចៅក្រមក្នុងការបង្គាប់ឲ្យអ្នកចុងចោទមកបង្ហាញខ្លួននៅតុលាការ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ។

**ដីកាបណ្តោះអាសន្ន** ៖ ក្នុងសំណុំរឿងក្រោមច្បាប់រក្សាការពារ ដីកាដែលចៅក្រមផ្តល់ឲ្យ ក្រោយពីអ្នកដើមចោទដាក់ពាក្យ *បណ្តឹង* ប៉ុន្តែចេញឲ្យមុនការធ្វើសវនាការសម្រេច ។ ដីកាបណ្តោះអាសន្នពុំមានសុពលភាពឡើយ បើអ្នកចុងចោទ នៅមិនទាន់ទទួលបាន

ឯកសារប្រៀបធៀប

សំណៅជូនដំណឹងអំពីដីកានេះទេនោះ (បានផ្តល់សេវាកម្មឲ្យ) ។ សូមមើល ដីកា និង ដីកាសម្រេច ផងដែរ ។

**អ្នកផ្តល់សេវាថែទាំដែលមិនបានប្រាក់ឈ្នួល** ៖ បុគ្គលដែលស្ម័គ្រចិត្តមើលថែទាំពេញម៉ោង ឬមួងម្ភាល ដល់នីតិជន នៅផ្ទះរបស់ នីតិជននោះ ដែលការថែទាំនេះ គឺស្រដៀងគ្នានឹងការថែទាំ ដែលសមាជិកគ្រួសារមើលថែបុគ្គលនោះដែរ ។

**ដោយគ្មានការធ្វើបុរេវិនិច្ឆ័យ** ៖ ការទាត់ចោលបណ្តឹង ដែលអនុញ្ញាតឲ្យអ្នកដើមចោទអាចដាក់ពាក្យប្តឹងសារថ្មី នៅពេលក្រោយ អំពីអង្គហេតុ ឬ ព្រឹត្តិការណ៍ដដែល ។ ការទាត់ចោលបណ្តឹងដោយការធ្វើបុរេវិនិច្ឆ័យតម្រូវឲ្យអ្នកដើមចោទធ្វើការចោទប្រកាន់ទៅលើអង្គហេតុ ឬ ព្រឹត្តិការណ៍ថ្មី ទើបអាចដាក់ពាក្យបណ្តឹងបាន ។

## ឧបសម្ព័ន្ធ"ក៖ "តុលាការមណ្ឌល

បើអ្នកមិនប្រាកដថា តើត្រូវយកសំណុំរឿងរបស់អ្នក ទៅប្តឹងតុលាការមណ្ឌលណាមួយ សូមចូលមកកាន់៖www.courts.maine.gov/maine_courts/findacourt/។ លេខសម្រាប់អ្នកប្រើ TTY របស់តុលាការមណ្ឌល ទាំងអស់គឺ 711 ជាខ្សែបញ្ជូនបន្ត នៅរដ្ឋមេន ។

**AUGUSTA**
1 Court Street, Suite 101,
Augusta, ME 04330
(207) 213-2800

**BANGOR**
78 Exchange Street,
Bangor, ME 04401
*207+561-2300

**BELFAST**
11 Market Street,
Belfast, ME 04915
*207+338-3107

**BIDDEFORD**
25 Adams Street,
Biddeford, ME 04005
*207+283-1147

**BRIDGTON**
3 Chase Street, Suite 2,
Bridgton, ME 04009
(207) 647-3535

**CALAIS**
382 South Street, Suite B,
Calais, ME 04619
(207) 454-2055

**CARIBOU**
144 Sweden Street, Suite 104,
Caribou,"ME 04736
(207) 493-3144

**DOVER-FOXCROFT**
159 East Main Street, Suite 21
Dover-Foxcroft, ME 04426
207564-2240

**ELLSWORTH**
50 State Street, Suite 2,
Ellsworth, ME 04605
(207) 667-7141

**FARMINGTON**
129 Main Street, Suite 1,
Farmington,"ME 04938
(207) 778-8200

**FORT KENT**
139 Market Street, Suite 101,
Fort"Kent, ME 04743
(207) 834-5003

**HOULTON**
26 Court Street, Suite 201,
Houlton,"ME 04730
(207) 532-2147

**LEWISTON**
អាសយដ្ឋានទំនាក់ទំនង ៖
71 Lisbon Street,
Lewiston, ME 04240
(207) 795-4801
អាសយដ្ឋានប្រៃសណីយ៍ ៖
P.O. Box 1345
Lewiston, ME 04243-1345

**LINCOLN**
52 Main Street,
Lincoln, ME 04457"*207+794-
8512

**MACHIAS**
អាសយដ្ឋានទំនាក់ទំនង ៖
85 Court Street,
Machias, ME 04654
(207) 255-3044
អាសយដ្ឋានប្រៃសណីយ៍ ៖
P.O. Box 526, Machias, ME
04654-0526

**MADAWASKA**
អាសយដ្ឋានទំនាក់ទំនង ៖
645 Main Street,
Madawaska."OG04756
(207) 728-4700
អាសយដ្ឋានប្រៃសណីយ៍ ៖
139 Market Street, Suite 101,
Fort Kent, ME 04743

**MILLINOCKET**
អាសយដ្ឋានទំនាក់ទំនង ៖
207 Penobscot Avenue,
Millinocket, ME 04462
207723-4786
អាសយដ្ឋានប្រៃសណីយ៍ ៖
52 Main Street,
Lincoln, ME 04457

**NEWPORT**
12 Water Street,
Newport, ME 04953
*207+368-5778

**PORTLAND**
205 Newbury Street,
Portland, ME 04101
(207) 822-4200

**PRESQUE ISLE**
27 Riverside Drive,
Presque Isle, ME 04769
(207) 764-2055

**ROCKLAND**
62 Union Street,
Rockland, ME 04841
*207+596-2240

**RUMFORD**
145 Congress Street,
Rumford, ME 04276
(207) 364-7171

**SKOWHEGAN**
47 Court Street,
Skowhegan, ME 04976
*207+474-9518

**SOUTH PARIS**
26 Western Avenue,
South Paris, ME 04281
(207) 743-8942

**SPRINGVALE**
447 Main Street,
Springvale, ME 04083
*207+459-1400

**WATERVILLE**
18 Colby Street,
Waterville, ME 04901
*207+873-2103

**WEST BATH**
101 New Meadows Road,
West Bath, ME 04530
(207) 442-0200

**WISCASSET**
អាសយដ្ឋានទំនាក់ទំនង ៖
32 High Street,
Wiscasset, ME 04578
(207) 882-6363
អាសយដ្ឋានប្រៃសណីយ៍ ៖
P.O. Box 249,
Wiscasset, ME 04578-0249

**YORK**
11 Chases Pond Road,
York, ME 03909
(207) 363-1230

សម្រាប់តែផ្ដល់ព័ត៌មានប៉ុណ្ណោះ។

# ឧបសម្ព័ន្ធ ខ□ ការិយាល័យនគរបាលតំបន់

ទំព័រព័ត៌មានទំនាក់ទំនងរបស់នគរបាលតំបន់ នៅក្នុងវិបសៃត៍ផ្នែកតុលាការ មានតំណភ្ជាប់ទៅកាន់វិបសៃត៍របស់នគរបាលតំបន់ទាំងអស់ ។ សូមមើល៖ www.courts.maine.gov/maine_courts/small_claims/sheriffs ។

**ANDROSCOGGIN**
2 Turner Street,
Auburn, ME 04210
*207+753-2500

**AROOSTOOK**
25 School Street, Suite 216,
Houlton,"ME 04730
(207) 532-3471

**CUMBERLAND**
36 County Way,
Portland, ME 04102
*207+774-1444

**FRANKLIN**
123 County Way,
Farmington, ME 04938
(207) 778-2680

**HANCOCK**
50 State Street, Suite 10,
Ellsworth, ME 04605
(207) 667-7575

**KENNEBEC**
125 State Street,
Augusta, ME 04330
*207+623-3614

**KNOX**
301 Park Street,
Rockland, ME 04841
*207+594-0429

**LINCOLN**
42 Bath Road, P.O. Box 611,
Wiscasset, ME 04578
(207) 882-6576

**OXFORD**
26 Western Avenue,
P.O. Box 179,
South Paris, ME 04281
(207) 743-9554

**PENOBSCOT**
85 Hammond Street,
Bangor, ME 04401
(207) 947-4585

**PISCATAQUIS**
52 Court Street,
Dover-Foxcroft, ME 04426
(207) 564-3304

**SAGADAHOC**
752 High Street, P.O. Box 246,
Bath, ME 04530
(207) 443-8528

**SOMERSET**
131 E. Madison Road,
Madison, ME 04950
(207) 474-9591

**WALDO**
11 Market Street,
Belfast, ME 04915
*207+338-6786

**WASHINGTON**
83 Court Street,
Machias, ME 04654
*207+255-4422

**YORK**
1 Layman Way,
Alfred, ME 04002
*207+324-1113

# ឧបសម្ព័ន្ធ គ៖ ព័ត៌មានទូទៅ

## ការសម្របសម្រួលចំពោះពិការភាព

ផ្នែកតុលាការរដ្ឋមេន ខិតខំប្រឹងប្រែងព្យាយាមគ្រប់យ៉ាង ដើម្បីផ្ដល់ការសម្របសម្រួល និងផ្ដល់ជំនួយ និងសេវាកម្មនានា ចំពោះជនដែលមានពិការភាព ដោយមិនយកកម្រៃ ដើម្បីឲ្យពួកគេ អាចមកកាន់ និងប្រើសេវាកម្មរបស់តុលាការ ។ អ្នកអាចពិភាក្សាជាមួយមេធាវីរបស់ខ្លួន អំពីការរៀបចំកិច្ចការសម្រួលនានា ឬក៏ទាក់ទងមកកាន់អ្នកសម្របសម្រួលផ្នែកប្រើប្រាស់សេវាកម្មតុលាការ (Court Access Coordinator) តាមរយៈលេខ 207-822-0718 ចំពោះអ្នកប្រើ TTY ៖ សេវាកម្មបញ្ជូនបន្ត របស់រដ្ឋមេន គឺលេខ 711 ឬទាក់ទងតាមaccessibility @courts.maine.gov ដើម្បីស្នើសុំការសម្របសម្រួល ។ អ្នកក៏អាចទាក់ទងមកកាន់ការិយាល័យក្រឡាបញ្ជីតុលាការ ដែលអ្នកបានដាក់ប្ដឹងសំណុំរឿងរបស់អ្នកផងដែរ ។ តំណភ្ជាប់ទៅកាន់ទម្រង់ស្នើសុំការសម្រួលដោយសារពិការភាព នៅក្នុងវិបសៃត៍ផ្នែកតុលាការ គឺមាននៅឯ ៖
www.courts.maine.gov/citizen_help/access_interp ។

## ការទទួលបានជំនួយផ្នែកភាសា

ផ្នែកតុលាការរដ្ឋមេន មានផ្ដល់ជូនអ្នកបកប្រែភាសា សម្រាប់បុគ្គលដែលភាពស្ទាត់ជំនាញផ្នែកភាសាអង់គ្លេសរបស់ខ្លួននៅមានកម្រិត (LEP) ឬសម្រាប់មនុស្សថ្លង់ ឬមនុស្សពិបាកស្ដាប់ ដោយមិនគិតថ្លៃ ដើម្បីឲ្យពួកគេអាចមកកាន់តុលាការ និងប្រើសេវាកម្មរបស់តុលាការ ។ ផ្នែកតុលាការ ក៏ត្រូវផ្ដល់ជូនអ្នកបកប្រែភាសា ASL ទៅអ្នកចូលអង្កេតការណ៍ ដែលជាមនុស្សថ្លង់ ឬពិបាកស្ដាប់ ទៅតាមការស្នើសុំ ។ សូមពិភាក្សាជាមួយមេធាវីរបស់អ្នក អំពីការរៀបចំអ្នកបកប្រែភាសា ឬក៏ទាក់ទងមកកាន់អ្នកឯកទេសផ្នែកទទួលបានការទំនាក់ទំនង (Communications Access Specialist) ដោយផ្ទាល់តាមទូរស័ព្ទលេខ 207-822-0703 សម្រាប់អ្នកប្រើ TTY ៖ សេវាកម្មបញ្ជូនបន្តរបស់រដ្ឋមេន គឺលេខ 711 ឬទាក់ទងតាមinterpreters@courts.maine.gov ដើម្បីស្នើសុំអ្នកបកប្រែ ។ អ្នកក៏អាចទាក់ទងទៅកាន់ការិយាល័យក្រឡាបញ្ជី របស់តុលាការដែលអ្នកយកសំណុំរឿងរបស់អ្នកទៅប្ដឹង ។ សម្រាប់ព័ត៌មានបន្ថែមអំពី ជំនួយអ្នកបកប្រែភាសា គឺមាននៅក្នុងវិបសៃត៍របស់ផ្នែកតុលាការ តាមអាសយដ្ឋាន ៖
www.courts.maine.gov/maine_courts/admin/interpreters/ ។

## សម្រាប់ការជូនជាព័ត៌មានប៉ុណ្ណោះ

សៀវភៅគោលការណ៍ណែនាំនេះ គឺសម្រាប់ជួយគូភាគីវិវាទក្នុងសំណុំរឿងការរក្សាការពារពីការរំលោភបំពាន និងសំណុំរឿងការរក្សាការពារពីការរុក គួន ឲ្យបានយល់ថាតើសំណុំរឿងប្រភេទនេះ ត្រូវចាប់ផ្ដើមចេញពីណា ហើយថាតើគេយកសំណុំរឿងបែបនេះទៅធ្វើអ្វីខ្លះ ។ ដើម្បី

ធ្វើឲ្យសៀវភៅគោលការណ៍ណែនាំនេះ កាន់តែងាយអាន ដំណើរការតុលាការ និងខ្លឹមសារច្បាប់ដែលពាក់ព័ន្ធ ត្រូវបានសង្ខេបឲ្យនៅខ្លី ។

សូមកុំគិតថាព័ត៌មានក្នុងសៀវភៅគោលការណ៍ណែនាំនេះ គឺជាការពណ៌នាពេញលេញអំពីច្បាប់ទាំងអស់ ដែលគេអាចយកមកប្រើក្នុងសំណុំរឿងការរក្សាការពារ ។ បើអ្នកមានសំណួរអំពីច្បាប់ ឬដំណើរការតុលាការ សូមសួរមេធាវីរបស់អ្នក ឬក៏ស្វែងរកជំនួយផ្លូវច្បាប់ ។

សម្រាប់តែព័ត៌មានប៉ុណ្ណោះ

## ចំណាំ

សម្រាប់តែផ្ដល់ព័ត៌មានប៉ុណ្ណោះ។

## ចំណាំ

សម្រាប់តែប្រើកព័ត៌មានប៉ុណ្ណោះ

ប្រសិនបើអ្នកគឺជាជនរងគ្រោះពីអំពើហិង្សា ការរំលោភបំពាន ឬការរុកគួន
ហើយជឿថាអ្នកកំពុងតែស្ថិតក្នុងភាពគ្រោះថ្នាក់ចំពោះមុខនោះ
សូមទូរស័ព្ទទៅលេខ 9-1-1 ។

សម្រាប់ជំនួយស្វែងរកសេវាកម្មបណ្តោះអាសន្ន នៅក្នុងមូលដ្ឋាន របស់អ្នក
សូមទូរស័ព្ទទៅលេខ 2-1-1 ។

**សេវាកម្មបញ្ជូនជនរងគ្រោះរបស់គណៈមេធាវីរដ្ឋមេន**
**(Maine State Bar Association Lawyer Referral Service)**
1-800-860-1460 www.mainebar.org/page/AttorneyRequest
($25 សម្រាប់ថ្លៃរដ្ឋបាល ដើម្បីជួយអ្នករកមេធាវីឯកជន បូករួមទាំងការពិគ្រោះយោបល់រយៈពេល 30 នាទី) ។

**សម្ព័ន្ធរដ្ឋមេនដើម្បីបញ្ចប់អំពើហិង្សាក្នុងគ្រួសារ**
**(Maine Coalition to End Domestic Violence)**
1-866-83-4HELP www.mcedv.org

**សម្ព័ន្ធរដ្ឋមេនប្រឆាំងការរំលោភផ្លូវភេទ**
**(Maine Coalition Against Sexual Assault)**
1-800-871-7741 www.mecasa.org

**មជ្ឈមណ្ឌលធនធានអន្តោប្រវេសន៍រដ្ឋមេន**
**(Immigrant Resource Center of Maine)**
207-753-0061 www.ircofmaine.org

**សេវាកម្មច្បាប់សម្រាប់មនុស្សចាស់**
**(Legal Services for the Elderly)**
1-800-750-5353 www.mainelse.org

**សម្ព័ន្ធស្ត្រីវ៉ាបាណាគី**
**(Wabanaki Women's Coalition)**
1-844-7NATIVE www.wabanakiwomenscoalition.org

**មជ្ឈមណ្ឌលតស៊ូមតិ ៖**
**Micmac** 207-551-3639
**Maliseet** 207-532-6401
**Indian Township Passamaquoddy** 207-214-1917
**Passamaquoddy Peaceful Relations** 1-877-853-2613
**Penobscot Nation** 207-631-4886

**ក្នុងនេះផងដែរ សូមអានទំព័រវិបរបស់ជំនួយផ្លូវច្បាប់ដើមស្រល់**
**(Pine Tree Legal Assistance)**
**ស្តីអំពីការរក្សាការពារពីការរំលោភបំពាន តាមអាសយដ្ឋាន**
ptla.org/protection-abuse-maine-first-steps-frequently-asked-questions

ការិយាល័យរដ្ឋបាលផ្នែកតុលាការរដ្ឋមេន នៃតុលាការ
1 Court Street, Suite 301, Augusta, Maine 04330
www.courts.maine.gov